ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ
តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# របាយការណ៍
# ស្ដីពី
# វឌ្ឍនភាព បញ្ហាប្រឈម និងទិសដៅ
# នៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

លេខាធិការដ្ឋាន គ.ជ.អ.ប

ខែមករា ឆ្នាំ២០១៨

# មាតិកា


I. **សារទតា** ........................................................ ០១

II. **សមិទ្ធផល និងបញ្ហាប្រឈមនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ** ........ ០៥

១. ការគ្រប់គ្រងការងារកំណែទម្រង់ ........................................ ០៥

២. ការរៀបចំស្ថាប័ននៃរដ្ឋបាលថ្នាក់ក្រោមជាតិ ............................ ១១

៣. ការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ .......... ១៥

៤. ការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ .............................. ១៨

៥. ការគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ...... ២២

III. **ទិសដៅរយៈពេល៣ឆ្នាំបន្ទាប់** ............................................ ២៥

IV. **សេចក្តីសន្និដ្ឋាន** ..................................................... ២៧

# របាយការណ៍ស្តីពី
# វឌ្ឍនភាព បញ្ហាប្រឈម និងទិសដៅ
# នៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

## I. សាវតា

សន្តិភាព និងស្ថេរភាពនយោបាយដែលកើតចេញកិច្ចខិតខំប្រឹងប្រែងប្រកបដោយឆន្ទៈមោះមុត និងចក្ខុវិស័យច្បាស់លាស់របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការសម្របសម្រួល និងការបង្រួបបង្រួមជាតិ គឺជាមូលដ្ឋានគ្រឹះសម្រាប់ការស្តារឡើងវិញ និងការអភិវឌ្ឍប្រទេសជាតិដែលទទួលរងនូវការបំផ្លិចបំផ្លាញយ៉ាងខ្ទេចខ្ទីដោយសង្គ្រាមស៊ីវិលរ៉ាំរ៉ៃដែលបានអូសបន្លាយពេលវេលាជាច្រើនទសវត្សរ៍ និងរបបប្រល័យពូជសាសន៍ដែលបានបំផ្លាញទាំងស្រុងនូវហេដ្ឋារចនាសម្ព័ន្ធសង្គមគ្រប់វិស័យ និងរចនាសម្ព័ន្ធ ប្រព័ន្ធរដ្ឋបាលគ្រប់ថ្នាក់ និងគ្រប់វិស័យ។

បន្ទាប់ពីទទួលបានសន្តិភាព ស្ថេរភាពនយោបាយ ឯកភាពជាតិ និងឯកភាពទឹកដីពេញលេញតាមរយៈការអនុវត្ត "នយោបាយឈ្នះ-ឈ្នះ" ដែលផ្តួចផ្តើមគំនិត និងដឹកនាំអនុវត្តដោយ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នាចុងទសវត្សរ៍ទី៩០ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយជាតិតាមរយៈយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ ទី២ និងទី៣ ដោយផ្តោតទៅលើការធ្វើកំណែទម្រង់ក្នុងវិស័យសំខាន់ៗនានា ដើម្បីធានាដល់ការបន្តរក្សា និងពង្រឹងសន្តិភាព ស្ថេរភាពនយោបាយ និងការជំរុញកិច្ចអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចប្រកបដោយសមធម៌ និងចីរភាព។

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការគឺជាកំណែទម្រង់វិស័យអភិបាលកិច្ចដ៏មានសារៈសំខាន់មួយរបស់រាជរដ្ឋាភិបាលដែលបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាល់ទី១ ទី២ និងទី៣ ដោយផ្តោតជាសំខាន់លើការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈនៅថ្នាក់ក្រោមជាតិ ឈរលើគោលការណ៍គន្លឹះនានានៃអភិបាលកិច្ចល្អ គឺគណនេយ្យភាព តម្លាភាព ប្រសិទ្ធភាព ការចូលរួម ការឆ្លើយតប នីតិរដ្ឋ និងការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គម។

គោលបំណងដ៏ទូលំទូលាយនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការគឺការបង្កើតនូវវប្បធម៌ប្រជាធិបតេយ្យនៅមូលដ្ឋានដោយមានការចូលរួមពីប្រជាពលរដ្ឋ ការលើកកម្ពស់គុណភាពសេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានដែលឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ ដើម្បីលើកស្ទួយគុណភាពនៃជីវិតរបស់ប្រជាពលរដ្ឋ និងចូលរួមកាត់បន្ថយភាពក្រីក្រប្រកបដោយប្រសិទ្ធភាព។

ផ្អែកលើគោលបំណង និងទស្សនវិស័យខាងលើ និងដោយផ្អែកលើស្ថានភាពនយោបាយ សង្គម និងសេដ្ឋកិច្ចបន្ទាប់ពីប្រទេសជាតិទទួលបានសន្តិភាព ឯកភាពជាតិ ឯកភាពទឹកដីពេញលេញនៅដើមឆ្នាំ១៩៩៩ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំសម្របសម្រួលឱ្យមានការស្រុះស្រួលគ្នាខាងនយោបាយ ដើម្បីចាប់ផ្តើមធ្វើការកែទម្រង់វិមជ្ឈការនៅថ្នាក់ឃុំ សង្កាត់។ ផ្អែកលើមូលដ្ឋាននៃការឯកភាពស្រុះស្រួលគ្នាខាងផ្នែកនយោបាយ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានអនុម័តនាឆ្នាំ២០០១ ហើយការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី១ត្រូវបានរៀបចំឡើងនាខែកុម្ភៈ ឆ្នាំ២០០២។

ការបង្កើតក្រុមប្រឹក្សាឃុំ សង្កាត់តាមរយៈការបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋតាមបែបប្រជាធិបតេយ្យ សេរី ពហុបក្ស គឺជាការកែទម្រង់ជាប្រវត្តិសាស្ត្រដែលធ្វើឱ្យផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងរដ្ឋបាលមូលដ្ឋាននៅថ្នាក់ឃុំ សង្កាត់ពីប្រព័ន្ធគ្រប់គ្រងតាមបែបមជ្ឈការ ដែលមេឃុំ ចៅសង្កាត់ត្រូវបានតែងតាំង និងមានតួនាទីផ្តោតទៅលើការគ្រប់គ្រងប្រជាពលរដ្ឋ និងរក្សាសន្តិសុខ សណ្តាប់ធ្នាប់នៅក្នុងដែនដីរបស់ខ្លួនទៅជាប្រព័ន្ធគ្រប់គ្រងតាមបែបវិមជ្ឈការ ដែលក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសដោយផ្ទាល់ពីប្រជាពលរដ្ឋ ធ្វើជាអ្នកតំណាងឱ្យសម្លេង និងផលប្រយោជន៍របស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននីមួយៗ ហើយមានតួនាទីសំខាន់ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋ ព្រមទាំងត្រូវមានគណនេយ្យ ភាពដោយផ្ទាល់ជាមួយប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ដើម្បីធានាឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ដើរតួនាទីជាតំណាងប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ត្រូវបានរៀបចំជាថ្មីដោយផ្អែកលើគោលការណ៍នានានៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អ។ នីតិវិធីអនុវត្តការងារ និងប្រព័ន្ធគ្រប់គ្រងសំខាន់ៗរបស់ឃុំ សង្កាត់ដែលត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តទាំងនោះរួមមាន៖ ១)នីតិវិធីរៀបចំកិច្ចប្រជុំជាសាធារណៈរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដែលធានាឱ្យការធ្វើសេចក្តីសម្រេចចិត្តនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់ប្រកបដោយការវិភាគព័ត៌មានគ្រប់ជ្រុងជ្រោយ និងមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយនឹងអ្នកពាក់ព័ន្ធនានា ២)ប្រព័ន្ធកសាងផែនការឃុំ សង្កាត់តាមបែបវិមជ្ឈការដោយមានការចូលរួមពីប្រជាពលរដ្ឋ តំណាងសហគមន៍ អង្គការសង្គមស៊ីវិល តំណាងក្រុមជនងាយរងគ្រោះ និងផ្នែកឯកជននៅមូលដ្ឋាន ៣)ការបង្កើតមូលនិធិឃុំ សង្កាត់ដើម្បីផ្តល់ធនធានហិរញ្ញវត្ថុដល់រដ្ឋបាលឃុំ សង្កាត់ក្នុងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ក្រោមឆន្ទានុសិទ្ធិរបស់ខ្លួន និង៤)ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ដែលធានាឱ្យការគ្រប់គ្រង ការចាត់ចែង ការប្រើប្រាស់ធនធានហិរញ្ញវត្ថុរបស់ឃុំ សង្កាត់សម្រាប់ការផ្តល់សេវាសាធារណៈ និងការអនុវត្តគម្រោងអភិវឌ្ឍនានា ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

ផ្អែកតាមនីតិវិធីអនុវត្តការងារ និងប្រព័ន្ធគ្រប់គ្រងនានាដែលបានដាក់ឱ្យអនុវត្ត រួមជាមួយនឹងការផ្តល់ការអភិវឌ្ឍសមត្ថភាព ការតាមដានត្រួតពិនិត្យ និងការគាំទ្រផ្នែកបច្ចេកទេសជាបណ្តើរៗបានធ្វើឱ្យក្រុមប្រឹក្សាឃុំ សង្កាត់មានសមត្ថភាព និងលទ្ធភាពក្នុងការអនុវត្តតួនាទីថ្មីរបស់ខ្លួនស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត មានការសម្របសម្រួលឱ្យមានការស្រុះស្រួល និងឯកភាពគ្នាក្នុងចំណោមសមាជិកក្រុមប្រឹក្សាដែលមកពីគណបក្សនយោបាយផ្សេងៗគ្នាក្នុងការធ្វើសេចក្តីសម្រេចចិត្តនានាទាំងគោលនយោបាយ និងកិច្ចការរដ្ឋបាលក្នុងការដឹកនាំ និងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់របស់ខ្លួនប្រកបដោយសុខដុមនីយកម្ម។

ជារួម ក្រោមក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបានធ្វើឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាននូវប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈនៅថ្នាក់ឃុំ សង្កាត់ ដោយបានបង្កលក្ខណៈឱ្យរដ្ឋបាលឃុំ សង្កាត់ទូទាំងប្រទេសដែលស្ថិតក្រោមការដឹកនាំចាត់ចែងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់សាមីនីមួយៗមានសមត្ថភាព និងលទ្ធភាពក្នុងការផ្តល់សេវាចាំបាច់នានា និងការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តខ្នាតតូច

និងគម្រោងមិនមែនហេដ្ឋារចនាសម្ព័ន្ធនានាជាច្រើន (ប្រមាណ១.៨០០គម្រោងក្នុងមួយឆ្នាំៗ) ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាអាទិភាព និងបានចូលរួមដោះស្រាយបញ្ហាប្រឈមជាក់ស្តែងនានារបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ផ្អែកតាមតម្រូវការ និងស្ថានភាពផ្សេងៗគ្នានៃឃុំ សង្កាត់ និងភូមិនានាចំណុះឃុំ សង្កាត់ទាំងនោះ។ គម្រោងអភិវឌ្ឍមូលដ្ឋានដែលបានរៀបចំ និងអនុវត្តក្រោមការទទួលខុសត្រូវ ការគ្រប់គ្រង ការចាត់ចែងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់រួមមានជាអាទិ៍ ការសាងសង់ផ្លូវលំជនបទ ស្ពាន ការដាក់លូកាត់ថ្នល់ អណ្តូងទឹក ស្រះទឹក ប្រព័ន្ធធារាសាស្ត្រខ្នាតតូច អគារសិក្សានៅតាមតំបន់ជនបទឆ្ងាយៗ និងគម្រោងផ្តល់សេវាផ្សេងៗពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាល ការផ្សព្វផ្សាយព័ត៌មានអំពីបញ្ហាសុខភាព និងអនាម័យតាមជនបទ ការផ្សព្វផ្សាយចំណេះដឹងអំពីបញ្ហាយេនឌ័រ ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការចងក្រងសហគមន៍តាមមូលដ្ឋានដើម្បីការពារនិងលើកស្ទួយផលប្រយោជន៍របស់ក្រុមជនងាយរងគ្រោះ និងការរៀបចំ និងអនុវត្តគម្រោងបង្កើនប្រាក់ចំណូលលក្ខណៈគ្រួសារ និងសហគមន៍នានា ដោយប្រើប្រាស់មូលនិធិឃុំ សង្កាត់ដែលខ្លួនមាន និងធនធាននានាដែលកៀរគរបានពីដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ការចូលរួមចំណែករបស់សប្បុរសជននានា និងប្រភពស្របច្បាប់ផ្សេងទៀត។ ក្រៅពីនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ក៏បានអនុវត្តនូវមុខងារជាភ្នាក់ងាររដ្ឋក្នុងការផ្តល់សេវាអគ្រានុកូលដ្ឋាន និងសេវារដ្ឋបាលផ្សេងទៀតយ៉ាងសកម្ម និងមានប្រសិទ្ធភាពជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនផងដែរ។

ការផ្លាស់ប្តូរជាវិជ្ជមាននេះបានបង្ហាញឱ្យឃើញថា ការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ បានរួមចំណែកយ៉ាងសំខាន់ក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន ការលើកកម្ពស់គុណភាពនៃការផ្តល់សេវា និងកិច្ចអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងបញ្ហាប្រឈមជាក់ស្តែងរបស់ប្រជាពលរដ្ឋតាមមូលដ្ឋានផ្សេងៗគ្នា ដែលជាការចូលរួមចំណែកយ៉ាងមានប្រសិទ្ធភាពក្នុងការកាត់បន្ថយភាពក្រីក្រ និងលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

ផ្អែកលើសមិទ្ធផល មេរៀន និងបទពិសោធន៍ដែលទទួលបានពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ បានជំរុញ និងលើកទឹកចិត្តដល់រាជរដ្ឋាភិបាលធ្វើការសម្រេចចិត្តក្នុងការពង្រីកកិច្ចដំណើរការកំណែទម្រង់នេះទៅរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀតនៅទូទាំងប្រទេស ដោយបានរៀបចំ និងដាក់ចេញនូវក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅឆ្នាំ២០០៥ ដើម្បីកំណត់នូវគោលការណ៍ និងយុទ្ធសាស្ត្រជាគន្លឹះសម្រាប់ជាផែនទីបង្ហាញផ្លូវដល់ការពង្រីកកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

កំណែទម្រង់នៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភាពសាំញ៉ាំ រសើប និងមានវិសាលភាពទូលំទូលាយ ព្រោះវាមិនគ្រាន់តែតម្រូវឱ្យមានការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យក្លាយជារដ្ឋបាលដែលគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាព និងកំណត់អំពីប្រភេទ និងចរិតលក្ខណៈផ្សេងៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដើម្បីធានាដល់ការរៀបចំបែបផែនគ្រប់គ្រងរដ្ឋបាលផ្សេងៗគ្នារវាងតំបន់ទីក្រុង ទីប្រជុំជន និងតំបន់ជនបទប៉ុណ្ណោះនោះទេ ក៏ប៉ុន្តែវាក៏តម្រូវឱ្យមានការកែសម្រួលឡើងវិញនូវតួនាទី និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិដែលចាំបាច់ត្រូវផ្តោតទៅលើការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រតាមវិស័យនីមួយៗ និងការផ្ទេរនូវមុខងារ ធនធាន និងបុគ្គលិកទៅឱ្យរដ្ឋបាលប្រភេទផ្សេងៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

ផ្អែកលើក្របខ័ណ្ឌយុទ្ធសាស្ត្រ វិសាលភាព និងភាពសាំញ៉ាំនៃកំណែទម្រង់ក្នុងដំណាក់កាលថ្មីនេះ តម្រូវឱ្យមានការធ្វើវិសោធនកម្មមាត្រា១៤៥ និងមាត្រា១៤៦នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីជំរុញដល់ការរៀបចំ និងអនុម័តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នាឆ្នាំ២០០៨។ ផ្អែកលើមូលដ្ឋានច្បាប់ទាំងនេះ នៅឆ្នាំ២០០៩ ការជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌសម្រាប់អាណត្តិទី១ តាមរយៈការបោះឆ្នោតអសកល ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស ក៏ត្រូវបានរៀបចំឡើង ដោយជ្រើសរើសបាននូវក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីបំពេញតួនាទីជាស្ថាប័ន ដែលមានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចចិត្តក្នុងការដឹកនាំ និងការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅដំណាក់កាលនេះ គឺជាកិច្ចដំណើរការកំណែទម្រង់ដែលមានលក្ខណៈស៊ីជម្រៅ និងសាំញ៉ាំជាងកិច្ចដំណើរការកំណែទម្រង់នៅថ្នាក់ឃុំ សង្កាត់។ អាស្រ័យហេតុនេះ ដើម្បីធានាដល់ការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌប្រកបដោយសនិទានភាព មានការគ្រោងទុក មានដំណាក់កាល មានការពិគ្រោះយោបល់ និងមានការសម្របសម្រួលគ្នាក្នុងចំណោមអ្នកពាក់ព័ន្ធនានាប្រកបដោយតម្លាភាព នៅឆ្នាំ២០១០ រាជរដ្ឋាភិបាលបានរៀបចំតាក់តែងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរយៈពេល១០ឆ្នាំ(២០១០-២០១៩) ដើម្បីធ្វើជាផែនទីបង្ហាញផ្លូវដល់ការអនុវត្តកិច្ចដំណើរការកំណែទម្រង់នេះ។ កម្មវិធីជាតិបានផ្តល់នូវផែនទីដោយផ្តោតលើការអនុវត្តកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការទៅតាមសមាសភាគសំខាន់ចំនួន៥គឺ៖

១) ការគ្រប់គ្រងការងារកំណែទម្រង់

២) ការរៀបចំស្ថាប័ននៃរដ្ឋបាលថ្នាក់ក្រោមជាតិ

៣) ការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

៤) ការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និង

៥) ការគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ជាមួយគ្នានេះ ដើម្បីធានាឱ្យកិច្ចដំណើរការកំណែទម្រង់ដែលមានលក្ខណៈសាំញ៉ាំនេះអាចអនុវត្តប្រកបដោយភាពច្បាស់លាស់ទៅតាមដំណាក់កាលនីមួយៗ ដោយមិនធ្វើឱ្យមានការរំខាន និងរាំងស្ទះដល់ការប្រព្រឹត្តទៅជាប្រចាំនៃស្ថាប័នសាធារណៈទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងអាចដោះស្រាយបាននូវហានិភ័យនានាដែលអាចកើតឡើងជាយថាហេតុ កម្មវិធីជាតិបានបែងចែកការអនុវត្តជា**៣ ដំណាក់កាល**ដូចខាងក្រោម៖

- **ដំណាក់កាលទី១៖** ជាផែនការអនុវត្ត៣ឆ្នាំដំបូង "ផអ៣ទី១" ដែលត្រូវបានកំណត់ឱ្យអនុវត្តក្នុងរយៈពេល៣ឆ្នាំ គិតចាប់ពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៣ ក៏ប៉ុន្តែដោយសារមានភាពយឺតយ៉ាវក្នុងការចាប់ផ្តើមអនុវត្តនៅក្នុងឆ្នាំ២០១១ ក៏បានតម្រូវឱ្យមានការពន្យារពេលនៃការអនុវត្តរយៈពេល១ឆ្នាំបន្ថែមទៀតនៅក្នុងឆ្នាំ២០១៤។ គោលបំណងសំខាន់នៃផអ៣ទី១នេះផ្តោតទៅលើ

ការរៀបចំលិខិតបទដ្ឋានគតិយុត្តចាំបាច់នានា ការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងនីតិវិធីអនុវត្តការងាររបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទំនាក់ទំនង និងការគាំទ្រនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដល់រដ្ឋបាលឃុំ សង្កាត់ ការអភិវឌ្ឍសមត្ថភាពដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តតាមប្រព័ន្ធ បែបបទ នីតិវិធីថ្មី ព្រមទាំងការរៀបចំកិច្ចដំណើរការ និងយន្តការនានាសម្រាប់ផ្ទេរមុខងារ និងធនធានទៅឱ្យដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

- **ដំណាក់កាលទី២៖** ជាផែនការអនុវត្ត៣ឆ្នាំដំណាក់កាលទី២ "ផអ៣ទី២" ដែលត្រូវបានកំណត់ឱ្យអនុវត្តចាប់ពីឆ្នាំ២០១៥ដល់ឆ្នាំ២០១៧ ដោយផ្តោតទៅលើការពង្រឹង និងការគាំទ្រលើការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រព័ន្ធ នីតិវិធី និងយន្តការនានាដែលបានរៀបចំបង្កើតនៅក្នុងដំណាក់កាលទី១ និងជាពិសេសជំរុញដល់ការផ្ទេរមុខងារ និងធនធានជាបណ្តើរៗទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- **ដំណាក់កាលទី៣៖** ជាផែនការអនុវត្ត៣ឆ្នាំដំណាក់កាលទី៣ "ផអ៣ទី៣" ដែលត្រូវអនុវត្តចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០ ដោយផ្តោតទៅលើការបន្តជំរុញ និងលើកកម្ពស់ការទទួលខុសត្រូវ និងស្វ័យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិលើការផ្តល់សេវាសាធារណៈ កិច្ចអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ដោយផ្អែកលើមេរៀន និងបទពិសោធន៍នៃការអនុវត្តក្នុងដំណាក់កាលទី២ ព្រមទាំងធ្វើការសិក្សាវាយតម្លៃ និងកែសម្រួលកម្មវិធីនានា ដើម្បីធានាឱ្យកិច្ចដំណើរការនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ឆ្លើយតប និងឆ្លុះបញ្ចាំងទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រថ្មីៗរបស់រាជរដ្ឋាភិបាល។

នៅចុងឆ្នាំ២០១៧កន្លងមកនេះ ផអ៣ទី២ត្រូវបានអនុវត្តដោយសម្រេចបានសមិទ្ធផលសំខាន់ៗ ដែលជាមូលដ្ឋានក្នុងការរៀបចំតាក់តែងផអ៣ទី៣ ដែលត្រូវដាក់ឱ្យអនុវត្តចាប់ពីឆ្នាំ២០១៨នេះតទៅ។ របាយការណ៍នេះឆ្លុះបញ្ចាំងអំពីសមិទ្ធផល បញ្ហាប្រឈម មេរៀនបទពិសោធន៍នៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការចាប់ពីឆ្នាំ២០០២មកដែលជាមូលដ្ឋានគ្រឹះក្នុងការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិតាមរយៈផអ៣ទី១ និងផអ៣ទី២ ដោយផ្តោតជាសំខាន់ទៅលើវឌ្ឍនភាពជាចម្បងៗ និងបញ្ហាប្រឈមនានាតាមសមាសភាគនីមួយៗនៃកម្មវិធីជាតិ និងកំណត់នូវទិសដៅជាគន្លឹះនានាសម្រាប់ការបន្តអនុវត្តនៅក្នុងផអ៣ទី៣ និងចក្ខុវិស័យទៅអនាគតនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

## II. សមិទ្ធផល និងបញ្ហាប្រឈមនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

### ១. ការគ្រប់គ្រងការងារកំណែទម្រង់

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺជាកិច្ចដំណើរការកំណែទម្រង់ដែលមានលក្ខណៈសាំញ៉ាំមានការពាក់ព័ន្ធយ៉ាងស៊ីជម្រៅទាំងក្នុងកិច្ចការនយោបាយ និងកិច្ចការគ្រប់គ្រងរដ្ឋបាលសាធារណៈ

របស់ស្ថាប័ននានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ អាស្រ័យហេតុនេះ ដើម្បីធានាឱ្យកិច្ចដំណើរការកំណែទម្រង់នេះប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាព តម្រូវឱ្យមានយន្តការគ្រប់គ្រងការងារកំណែទម្រង់ដ៏រឹងមាំមួយ ដើម្បីដឹកនាំ និងសម្របសម្រួលកិច្ចដំណើរការកំណែទម្រង់នេះ។ ក្នុងដំណាក់កាលនៃកំណែទម្រង់នៅថ្នាក់ឃុំ សង្កាត់នាឆ្នាំ២០០២ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់បានតម្រូវឱ្យបង្កើតយន្តការសម្របសម្រួលអន្តរស្ថាប័នមួយ ដើម្បីគាំទ្រ និងជំរុញកិច្ចដំណើរការកំណែទម្រង់នេះដែលមានឈ្មោះថា " គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់" ដែលហៅកាត់ថា គ.ឃ.ស. ។ ក្នុងអាណត្តិរបស់ខ្លួន គ.ឃ.ស. បានធ្វើការសម្របសម្រួលក្នុងចំណោមក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានាក្នុងការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធ និងនីតិវិធីនានាសម្រាប់ការបំពេញការងាររបស់រដ្ឋបាលឃុំ សង្កាត់ស្របតាមគោលនយោបាយវិមជ្ឈការដែលមានលក្ខណៈថ្មីថ្មោងបំផុតក្នុងប្រព័ន្ធនៃការគ្រប់គ្រងរដ្ឋបាលនៅកម្ពុជា។ អាស្រ័យដោយការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងកិច្ចដំណើរការកំណែទម្រង់ និងដោយមានការចូលរួមគាំទ្រពីក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានាក្រោមការសម្របសម្រួលរបស់ គ.ឃ.ស. បានធ្វើឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាប់ឆ្នោតដំបូងនាឆ្នាំ២០០២ ចាប់ផ្តើមបំពេញការងាររបស់ខ្លួនយ៉ាងរលូនក្នុងរចនាសម្ព័ន្ធថ្មីតាមបែបប្រជាធិបតេយ្យ និងវិមជ្ឈការ ដែលសមិទ្ធផលទាំងនេះគឺជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់រដ្ឋបាលឃុំ សង្កាត់នាអាណត្តិជាបន្តបន្ទាប់ក្នុងការអនុវត្តការងាររបស់ខ្លួនរហូតមក។ ផ្អែកតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានតម្រូវឱ្យ គ.ឃ.ស. បញ្ចប់អាណត្តិរបស់ខ្លួនរយៈពេល០៦ខែមុនការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី២ ប៉ុន្តែការសម្របសម្រួលកិច្ចដំណើរការកំណែទម្រង់ដ៏ថ្មីថ្មោងនេះមិនបានបញ្ចប់នោះឡើយ។ ទន្ទឹមនេះនៅពេលនោះ រាជរដ្ឋាភិបាលក៏នៅមានតម្រូវការចាំបាច់ក្នុងការធ្វើសុខដុមនីយកម្មរវាងស្ថាប័ននានា ដែលទទួលខុសត្រូវក្នុងកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ កម្មវិធីសិលាកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ ស្របពេលដែលរាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តពង្រីកកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅរដ្ឋបាលថ្នាក់ក្រោមជាតិទាំងមូលតាមរយៈការរៀបចំយុទ្ធសាស្ត្រជាតិស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការសម្រាប់ជាមូលដ្ឋានក្នុងការរៀបចំ តាក់តែងច្បាប់រៀបចំអង្គការសម្រាប់ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ អាស្រ័យដោយតម្រូវការចាំបាច់ទាំងនេះ រាជរដ្ឋាភិបាលបានបង្កើតឡើងនូវ " គណៈកម្មាធិការជាតិដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ" ដែលហៅកាត់ថា គ.ជ.វ.វ. សម្រាប់បន្តដឹកនាំសម្របសម្រួលកិច្ចដំណើរការកំណែទម្រង់នេះ បន្តពី គ.ឃ.ស.។ ផ្អែកលើបទពិសោធន៍នេះ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌបានតម្រូវឱ្យរៀបចំបង្កើតនូវគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលហៅកាត់ថា **គ.ជ.អ.ប.** និងយន្តការនានានៃ គ.ជ.អ.ប. ដែលជាស្ថាប័នអចិន្ត្រៃយ៍មួយជាសេនាធិការឱ្យរាជរដ្ឋាភិបាលដើម្បីបន្តនិរន្តរភាពការងារពីគ.ជ.វ.វ.ក្នុងការដឹកនាំ និងសម្របសម្រួលក្រសួង ស្ថាប័ន ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាក្នុងការគាំទ្រ និងការចូលរួមអនុវត្តកិច្ចដំណើរការកំណែទម្រង់នេះរហូតមកទល់បច្ចុប្បន្ន។

ពាក់ព័ន្ធនឹងការគ្រប់គ្រងការងារកំណែទម្រង់នេះ កម្មវិធីជាតិបានកំណត់នូវកិច្ចការអាទិភាពនានាដែលត្រូវរៀបចំ និងអនុវត្តក្រោមក្របខ័ណ្ឌនៃការដឹកនាំ និងការសម្របសម្រួលរបស់ គ.ជ.អ.ប. ដែលក្នុង

នោះរួមមាន៖

១) ការរៀបចំគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា

២) ការគ្រប់គ្រងការរៀបចំ និងការអនុវត្តផែនការ កម្មវិធី និងគម្រោងនានា

៣) ការអភិវឌ្ឍសមត្ថភាព និងការគាំទ្របច្ចេកទេស

៤) ការគាំទ្រក្រសួង ស្ថាប័នក្នុងការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

៥) ការគាំទ្រសមាគមក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ និង

៦) ការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន។

**ក. វឌ្ឍនភាព**

ក្នុងអំឡុងពេលនៃការអនុវត្តផអ៣ទី១ និងផអ៣ទី២នៃកម្មវិធីជាតិអស់រយៈពេល៧ឆ្នាំកន្លងមកនេះ(២០១០-២០១៧) ដោយមានលេខាធិការដ្ឋាន គ.ជ.អ.ប ជាសេនាធិការ គ.ជ.អ.ប បានរៀបចំកិច្ចប្រជុំយ៉ាងហោចចំនួន២ដងក្នុងមួយឆ្នាំ ដើម្បីពិនិត្យ ពិភាក្សា ពិគ្រោះយោបល់ ធ្វើការសម្រេចចិត្ត និងផ្តល់គោលការណ៍ណែនាំតម្រង់ទិសកម្រិតនយោបាយលើការគ្រប់គ្រងការងារកំណែទម្រង់ ដោយបានធ្វើឱ្យកិច្ចដំណើរការកំណែទម្រង់នេះមានការវិវឌ្ឍជឿនលឿនទៅមុខជាលំដាប់ ព្រមទាំងសម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើន រួមមានជាអាទិ៍៖

- លិខិតបទដ្ឋានគតិយុត្តសំខាន់ៗប្រមាណជាង៣០០ពាក់ព័ន្ធនឹងការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រង នីតិវិធីអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ កិច្ចដំណើរការផ្ទេរមុខងារ ធនធាន សិទ្ធិអំណាច ការទទួលខុសត្រូវទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ យន្តការនិងយុទ្ធសាស្ត្រអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ យន្តការត្រួតពិនិត្យនីត្យានុកូលភាព ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ ដាក់ឱ្យអនុវត្ត និងកែសម្រួលជាបណ្តើរៗដើម្បីជានាដល់ការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្ត។ លិខិតបទដ្ឋានគតិយុត្តដែលបានរៀបចំ និងដាក់ឱ្យអនុវត្តទាំងនោះរួមមាន ច្បាប់ចំនួន០៧ ឯកសារគោលនយោបាយចំនួន០២ ព្រះរាជក្រឹត្យចំនួន០៧ អនុក្រឹត្យចំនួន៩០ ប្រកាសចំនួន៨៧ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតចំនួនជាង១០០។
- ផែនការអនុវត្ត៣ឆ្នាំដំណាក់កាលទី១ (ផអ៣ទី១) ផែនការអនុវត្ត៣ឆ្នាំដំណាក់កាលទី២ (ផអ៣ទី២) ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ (ផ.ស.ថ) របស់ គ.ជ.អ.ប ដែលជាមធ្យោបាយដ៏មានសារៈសំខាន់សម្រាប់ការអនុវត្តកម្មវិធីជាតិ ត្រូវបានរៀបចំតាក់តែង និងគ្រប់គ្រងការអនុវត្តផែនការទាំងនោះប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងសុខដុមនីយកម្មទាំងក្នុងក្របខ័ណ្ឌកម្មវិធីកំណែទម្រង់សំខាន់ៗផ្សេងទៀត រួមមានដូចជាកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីកំណែទម្រង់តាមវិស័យនានា ព្រមទាំងក្នុងក្របខ័ណ្ឌនៃកម្មវិធី ឬគម្រោងនានារបស់ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល។ ជារួម ផអ៣ទី១ ផអ៣ទី២ និងផ.ស.ថ. ប្រចាំឆ្នាំរបស់ គ.ជ.អ.ប. ត្រូវបានរៀបចំ និងអនុវត្តជាបន្តបន្ទាប់តាមការកំណត់ដោយមានការពិនិត្យ ពិភាក្សា ពិគ្រោះយោបល់ និងការចូលរួមយ៉ាងទូលំទូលាយពីក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ

ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានានៅទូទាំងប្រទេស។ គិតមកដល់ឆ្នាំ ២០១៧ រាជរដ្ឋាភិបាលបានចំណាយថវិកាប្រមាណ**៨.១១២ពាន់លានរៀល**សមមូលនឹង **២.០០០ លានដុល្លារ** និងបានកៀរគរការចូលរួមគាំទ្រពីដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធនានានូវថវិកាសរុបប្រមាណជាង**៥៧០លានដុល្លារ** ដើម្បីចូលរួមគាំទ្រដល់កិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការតាមរយៈការអនុវត្ត ផ.ស.ថ ប្រចាំឆ្នាំរបស់ គ.ជ.អ.ប. ទាំងនេះ។

- ក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន២១ និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទូទាំងប្រទេសបានចូលរួមអនុវត្ត ផ.ស.ថ. ប្រចាំឆ្នាំរបស់ គ.ជ.អ.ប. តាមរយៈការរៀបចំនូវសេចក្តីសម្រេចរួមក្នុងទម្រង់ជាកិច្ចព្រមព្រៀងអនុវត្តការងារ ដែលធានាដល់ការលើកកម្ពស់ភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទាំងនោះក្នុងការអនុវត្តសកម្មភាពស្នូលនៃកំណែទម្រង់ដែលបានកំណត់នៅក្នុង ផ.ស.ថ ប្រចាំឆ្នាំរបស់ គ.ជ.អ.ប.។ ធនធានថវិកាជាមធ្យមចំនួនប្រមាណ**១២លាន**ដុល្លារក្នុង១ឆ្នាំៗ ត្រូវបានកៀរគរពីដៃគូអភិវឌ្ឍន៍នានាដើម្បីវិភាជន៍ និងផ្តល់ការគាំទ្រផ្នែកបច្ចេកទេសឱ្យទៅក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនីមួយៗសម្រាប់គាំទ្រដល់ការអភិវឌ្ឍសមត្ថភាព និងប្រតិបត្តិការក្នុងការអនុវត្តសកម្មភាពស្នូលនៃកំណែទម្រង់របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះ។
- ក្នុងកិច្ចដំណើរការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រៅពីការរៀបចំលិខិតបទដ្ឋានគតិយុត្តនានា គ.ជ.អ.ប. បានសម្របសម្រួល និងដឹកនាំឱ្យមានការពិនិត្យ ពិភាក្សា និងពិគ្រោះយោបល់ជាប្រចាំក្នុងចំណោមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងនៅក្នុងកិច្ចដំណើរការកំណត់នូវមុខងារ កិច្ចដំណើរការរៀបចំលិខិតបទដ្ឋាន និងកិច្ចដំណើរការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រោមការដឹកនាំ សម្របសម្រួលរបស់ គ.ជ.អ.ប. រហូតដល់ពេលនេះ មុខងារចំនួន១៨ត្រូវបានក្រសួង ស្ថាប័នចំនួន០៧កំណត់ជាផែនការក្នុងការផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិជាបណ្តើរៗទាំងក្នុងបែបផែននៃការធ្វើប្រតិកម្ម និងការប្រគល់នូវមុខងារទាំងនោះ។
- ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តតួនាទីរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិដូចបានកំណត់នៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា គ.ជ.អ.ប បានផ្តល់ការគាំទ្រទាំងផ្នែកបច្ចេកទេស និងថវិកាក្នុងការរៀបចំបង្កើតសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងគោលបំណង ដើម្បីឱ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមានបណ្តាញការងាររបស់ខ្លួនដែលមានលក្ខណៈឯករាជ្យ និងស្វ័យភាពសម្រាប់ការចែករំលែកព័ត៌មាន មេរៀន បទពិសោធន៍ ការលើកឡើងនូវបញ្ហាប្រឈមនានាដែលត្រូវរួមគ្នាដោះស្រាយ និងសំណើសំណូមពរនានាដែលត្រូវដាក់ជូន គ.ជ.អ.ប ឬរាជរដ្ឋាភិបាលពិនិត្យ ពិចារណាក្នុងកិច្ចដំណើរការរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា។ ជារួម បច្ចុប្បន្ន សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិចំនួន២ គឺសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត និងសម្ព័ន្ធភាពជាតិសមាគម

ក្រុមប្រឹក្សារដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ត្រូវបានបង្កើត និងដំណើរការដោយមានអគ្គលេខាធិការដ្ឋានសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិធ្វើជាសេនាធិការ។

- ប្រព័ន្ធតាមដាន និងត្រួតពិនិត្យជាប្រចាំលើការអនុវត្ត ផ.ស.ថ ប្រចាំឆ្នាំរបស់ គ.ជ.អ.ប. ត្រូវបានរៀបចំ កែសម្រួល និងដាក់ឱ្យអនុវត្តជាប្រចាំតាមប្រព័ន្ធកុំព្យូទ័រ ដែលបានផ្តល់លក្ខណៈងាយស្រួលដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក្នុងការធ្វើរបាយការណ៍អំពីវឌ្ឍនភាព និងបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងការអនុវត្ត ផ.ស.ថ. ប្រចាំឆ្នាំរបស់ គ.ជ.អ.ប ជូន គ.ជ.អ.ប.បានទាន់ពេលវេលា។ ការវាយតម្លៃដោយឯករាជ្យលើការអនុវត្តផអ៣ទី១ និងការវាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្តកម្មវិធីជាតិត្រូវបានអនុវត្តនៅឆ្នាំ២០១៣ និងឆ្នាំ២០១៦។ ក្រៅពីប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃជាទៀងទាត់លើការអនុវត្ត ផ.ស.ថ. ប្រចាំឆ្នាំរបស់ គ.ជ.អ.ប. ប្រព័ន្ធទិន្នន័យព័ត៌មាននានាក៏ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តសម្រាប់បម្រើឱ្យគោលបំណងនៃការកសាងផែនការ និងការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ ការអង្កេតផ្នែកអភិបាលកិច្ច ដើម្បីវាយតម្លៃលើប្រសិទ្ធភាពការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានដោយប្រៀបធៀបទៅនឹងគោលការណ៍អភិបាលកិច្ចល្អក៏ត្រូវបានរៀបចំឡើងក្នុងរយៈពេល២ឆ្នាំម្តង ហើយលទ្ធផលនៃការអង្កេតក៏ត្រូវបានបោះពុម្ពផ្សព្វផ្សាយជាសាធារណៈផងដែរ។ ផ្អែកតាមលទ្ធផលនៃការអង្កេតផ្នែកអភិបាលកិច្ចបានបង្ហាញឱ្យឃើញថា ការពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន រួមមានដូចជា ការចុះបញ្ជីអត្រានុកូលដ្ឋាន ការសម្រុះសម្រួលវិវាទនៅមូលដ្ឋាន ការសាងសង់ផ្លូវលំ ការផ្គត់ផ្គង់ទឹកស្អាត ការលើកកម្ពស់អនាម័យជនបទ ការគ្រប់គ្រងសំណល់ និងការសាងសង់ជារាសាស្ត្រខ្នាតតូច មានការកើនឡើងពី៥៨%នៅឆ្នាំ២០១៣ ដល់៦៦%នៅឆ្នាំ២០១៦ ។ យុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង និងផ្សព្វផ្សាយព័ត៌មានត្រូវបានរៀបចំ ដាក់ឱ្យអនុវត្ត និងកែសម្រួលជាបណ្តើរៗ ដើម្បីបង្កើនការផ្សព្វផ្សាយព័ត៌មានស្តីពីចក្ខុវិស័យ និងការវិវឌ្ឍនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឱ្យបានកាន់តែទូលំទូលាយដល់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងសាធារណជន។

**៩. បញ្ហាប្រឈម**

ទន្ទឹមជាមួយនឹងវឌ្ឍនភាពជាច្រើនដូចបានរៀបរាប់ខាងលើ ក៏នៅមានបញ្ហាប្រឈម និងការងារជាអាទិភាពមួយចំនួនដែលត្រូវដោះស្រាយ និងសម្របសម្រួលដូចខាងក្រោម ៖

- ផ្អែកលើបទពិសោធន៍នៃកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរយៈពេលជាងមួយទសវត្សរ៍កន្លះនៅកម្ពុជា ក៏ដូចជាបទពិសោធន៍នៅប្រទេសនានា ដំណើរការកំណែទម្រង់នេះ ទាមទារឱ្យតម្កល់ការប្តេជ្ញាចិត្តខាងនយោបាយ រយៈពេលវែងក្នុងចំណោមក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាក្នុងការគាំទ្រ និងការចូលរួមអនុវត្ត ពីព្រោះកំណែទម្រង់នេះជាដំណើរការមួយដែលតម្រូវឱ្យមានការផ្លាស់ប្តូរឥរិយាបថ និងទម្លាប់ក្នុងការគ្រប់គ្រងនៅគ្រប់ថ្នាក់ និងគ្រប់វិស័យក្នុងការកំណត់ និងបែងចែកឡើងវិញនូវមុខងារ ធនធាន ការទទួលខុសត្រូវ និងស្វ័យភាពរវាងរដ្ឋបាលនានានៅថ្នាក់ក្រោមជាតិ និងរវាងរដ្ឋបា

លថ្នាក់ក្រោមជាតិជាមួយក្រសួង ស្ថាប័ននានា។ ពាក់ព័ន្ធនឹងចំណុចដ៏សំខាន់នេះ ក្នុងអំឡុងពេលនៃការអនុវត្តកម្មវិធីជាតិ ក្រសួង ស្ថាប័នមួយចំនួននៅពុំទាន់ស្រុះស្រួលមូលគំនិតគ្នាទាំងស្រុងអំពីការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ជាពិសេសក្នុងក្របខ័ណ្ឌនៃស្វ័យភាព និងការទទួលខុសត្រូវក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងខណៈដែលកិច្ចដំណើរការកំណែទម្រង់នេះឈានចូលដំណាក់កាលកាន់តែស៊ីជម្រៅ ក្រសួង ស្ថាប័នមួយចំនួននៅតែមានភាពស្ទាក់ស្ទើរក្នុងការអនុវត្តតាមគោលនយោបាយនេះ ជាពិសេសក្នុងការសម្រេចចិត្តលើការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ប្រការនេះ ចាំបាច់ត្រូវពង្រឹងការប្តេជ្ញាចិត្តខាងនយោបាយរបស់ក្រសួង ស្ថាប័ននានា និងពង្រឹងការអនុវត្តតួនាទីរបស់គ.ជ.អ.ប. ក្នុងការសម្របសម្រួលកិច្ចដំណើរការកំណែទម្រង់ជាបន្តទៀត។

- ការចំណាយសម្រាប់គាំទ្រដល់ការអនុវត្តសកម្មភាពស្នូលនៃកំណែទម្រង់តាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ រួមមានដូចជា ការរៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការសិក្សាស្រាវជ្រាវ ការវាយតម្លៃ ការគាំទ្រជំនួយបច្ចេកទេស និងការអភិវឌ្ឍសមត្ថភាពនានា បានពឹងផ្អែកស្ទើរតែទាំងស្រុងលើធនធានដែលកៀរគរបានពីការចូលរួមគាំទ្ររបស់ដៃគូអភិវឌ្ឍនានា។ ប្រការនេះ ដើម្បីធានាដល់ការដឹកនាំសម្របសម្រួលកិច្ចដំណើរការកំណែទម្រង់ប្រកបដោយនិរន្តរភាព ទាមទារឱ្យមានការពង្រឹងភាពជាម្ចាស់របស់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តកិច្ចដំណើរការកំណែទម្រង់នេះតាមរយៈការបញ្ជ្រាបសកម្មភាពស្នូលនានានៃកំណែទម្រង់នេះទៅក្នុងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដោយប្រើប្រាស់ថវិការដ្ឋតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់រ៉ាប់រងលើការចំណាយក្នុងការអនុវត្តសកម្មភាពស្នូលនៃកំណែទម្រង់ទាំងនោះ។
- ដើម្បីបម្រើសំណូមពរនៃកំណែទម្រង់ចាប់ពីដំណាក់កាលពីដំបូងៗមកដល់បច្ចុប្បន្ន មានលិខិតបទដ្ឋានជាច្រើនត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត។ ក្នុងនោះលិខិតបទដ្ឋានមួយចំនួនត្រូវបានរៀបចំដោយពុំបានសម្របសម្រួលគ្នា លិខិតបទដ្ឋានមួយចំនួនទៀតត្រូវបានរៀបចំដោយពុំបានផ្អែកលើប្រព័ន្ធគ្រប់គ្រងបែបវិមជ្ឈការ និងច្បាប់រៀបចំអង្គការ ហើយលិខិតបទដ្ឋានខ្លះទៀតក៏មានលក្ខណៈសាំញ៉ាំធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិពិបាកយល់ និងមិនអាចអនុវត្តបាន។ ប្រការនេះតម្រូវឱ្យមានការពិនិត្យឡើងវិញលើលិខិតបទដ្ឋានគតិយុត្តនានាដែលបានដាក់ចេញកន្លងមក ដើម្បីកែសម្រួលឱ្យមានលក្ខណៈស៊ីសង្វាក់គ្នា ស្របតាមប្រព័ន្ធគ្រប់គ្រងវិមជ្ឈការ និងវិសហមជ្ឈការ ដែលកំណត់ដោយច្បាប់រៀបចំអង្គការ និងរៀបចំលិខិតបទដ្ឋានឱ្យកាន់តែមានលក្ខណៈសាមញ្ញ ងាយយល់ និងងាយស្រួលក្នុងការអនុវត្តជាក់ស្តែងនៅតាមមូលដ្ឋាន។
- ការយល់ដឹងអំពីចក្ខុវិស័យ និងកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅមានកម្រិតនៅឡើយ ដែលប្រការនេះទាមទារឱ្យមានការពង្រឹងការផ្សព្វផ្សាយព័ត៌មានឱ្យបាន

កាន់តែទូលំទូលាយថែមទៀត ទាំងនៅក្នុងស្ថាប័នរដ្ឋ ផ្នែកឯកជន អង្គការសង្គមស៊ីវិល និងសាធារណជន។

## ២. ការរៀបចំស្ថាប័ននៃរដ្ឋបាលថ្នាក់ក្រោមជាតិ

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់តាមបែបប្រជាធិបតេយ្យកាលពីជាង១៦ឆ្នាំមុន បានបង្កើតឡើងនូវក្រុមប្រឹក្សាដែលជាស្ថាប័នអភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិបតេយ្យ និងវិមជ្ឈការលើកដំបូងនៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលមូលដ្ឋាននៅកម្ពុជា។ ក្រុមប្រឹក្សាដែលជាប់ឆ្នោតទាំងនេះ និងរដ្ឋបាលរបស់ខ្លួនដែលមានរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងត្រូវបានរៀបចំជាថ្មីផ្អែកលើមូលដ្ឋាននៃការចូលរួម តម្លាភាព និងគណនេយ្យភាព គឺជាមូលធនសង្គមដ៏មានសក្តានុពលក្នុងការផ្តួចផ្តើមបង្កើតឡើងនូវវប្បធម៌នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋានដែលមានការឆ្លើយតប និងមានគណនេយ្យភាពជាចម្បងចំពោះប្រជាពលរដ្ឋតាមសហគមន៍នៅតាមមូលដ្ឋាននីមួយៗ។ សមិទ្ធផលដែលសម្រេចបានតាមរយៈការបង្កើតឡើងនូវស្ថាប័នអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៅថ្នាក់ឃុំ សង្កាត់បានលើកទឹកចិត្តដល់រាជរដ្ឋាភិបាលក្នុងការពង្រីកកិច្ចដំណើរការកំណែទម្រង់នេះឱ្យកាន់តែស៊ីជម្រៅថែមទៀតនៅថ្នាក់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងមូល។

ក្របខ័ណ្ឌយុទ្ធសាស្រ្តស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានតម្រូវឱ្យបង្កើតឡើងនូវក្រុមប្រឹក្សានៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមរយៈការបោះឆ្នោតអសកល និងតម្រូវឱ្យមានការរៀបចំឡើងវិញនូវស្ថាប័ននៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយឈរលើគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីធានាដល់ការបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ក្នុងន័យនេះ កម្មវិធីជាតិបានកំណត់នូវកិច្ចការសំខាន់ៗ ដែលត្រូវអនុវត្តតាមដំណាក់កាលជាក់លាក់នានា ដើម្បីធានាដល់ការបង្កើតបាននូវស្ថាប័ននៃរដ្ឋបាល ថ្នាក់ក្រោមជាតិដែលមានលទ្ធភាព និងសមត្ថភាពក្នុងការសម្របសម្រួលរាល់សកម្មភាពរដ្ឋបាលសាធារណៈទាំងអស់ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍនានា ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។ កិច្ចការជាអាទិភាពសំខាន់ៗដែលបានកំណត់ទាំងនោះរួមមាន

១) រៀបចំឡើងវិញនូវរចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

២) រៀបចំប្រព័ន្ធគ្រប់គ្រង និងនីតិវិធីអនុវត្តការងារតាមគោលការណ៍នៃអភិបាលកិច្ចល្អ

៣) ការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គមក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

៤) ការរៀបចំ និងការអនុវត្តនូវកម្មវិធីនានាដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ

៥) ការរៀបចំប្រព័ន្ធកម្មវិធីព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ក. វឌ្ឍនភាព**

ក្នុងអំឡុងពេលនៃការអនុវត្តផអ៣ទី១ និងផអ៣ទី២នៃកម្មវិធីជាតិអស់រយៈពេលជាង៧ឆ្នាំកន្លងមកនេះ(២០១១-២០១៧) មានសមិទ្ធផលធំៗជាច្រើនត្រូវបានបង្កើតឡើងពាក់ព័ន្ធនឹងការរៀបចំឡើង

វិញនូវស្ថាប័ននៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយឈរលើគោលការណ៍នៃរដ្ឋបាលឯកភាព និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ សមិទ្ធផលធំៗទាំងនោះរួមមាន៖

- ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ចាប់ពីអាណត្តិទី១រហូតដល់អាណត្តិទី៤នេះ ត្រូវបានរៀបចំឡើងតាមអាណត្តិរយៈពេល៥ឆ្នាំដែលកំណត់ដោយច្បាប់ស្តីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ខណ្ឌដែលបានកើតឡើងពីការបោះឆ្នោតអសកលដោយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង ដែលក្នុងអាណត្តិទី១រួមមានសមាជិកក្រុមប្រឹក្សារាជធានី ខេត្តចំនួន៣៧៤រូប សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន២.៨៨០រូប និងក្នុងអាណត្តិទី២ មានសមាជិកក្រុមប្រឹក្សារាជធានី ខេត្តចំនួន៣៩៣រូប និងសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន២.៩៣១រូប។ ក្រុមប្រឹក្សាទាំងនេះជាស្ថាប័នអភិបាលកិច្ចដ៏មានសក្តានុពលក្នុងការធ្វើសេចក្តីសម្រេចចិត្តក្នុងការគ្រប់គ្រង និងចាត់ចែងការងាររបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនីមួយៗ។ រចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទូទាំងប្រទេសត្រូវបានកែសម្រួល និងដាក់ឱ្យដំណើរការដោយរលូនតាមផែនការដែលបានកំណត់ ដោយរក្សាបាននូវការបន្តនិរន្តរភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។ គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ត្រីនៃសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលក្នុងអាណត្តិទី១ រួមមានគណៈអភិបាលនៃរដ្ឋបាលរាជធានី ខេត្តចំនួន១៦០រូប មន្ត្រីចំនួន២.៦៣៨រូប គណៈអភិបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន៩៣៤រូប មន្ត្រីចំនួន៤.៧០២រូប ក្នុងអាណត្តិទី២ មានគណៈអភិបាលនៃរដ្ឋបាលរាជធានី ខេត្តចំនួន១៧៥រូប មន្ត្រីចំនួន២.៧៦២រូប គណៈអភិបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន៩៥៥រូប មន្ត្រីចំនួន៥.២៤៦រូប ក៏ត្រូវបានតែងតាំង និងធ្វើសមាហរណកម្មដោយរលូនចូលទៅក្នុងរចនាសម្ព័ន្ធថ្មីនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌសាមី ដើម្បីដើរតួនាទីជាអង្គប្រតិបត្តិក្នុងការអនុវត្តសេចក្តីសម្រេចចិត្តនានារបស់ក្រុមប្រឹក្សានៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌសាមីរបស់ខ្លួន។
- នីតិវិធីអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបង្កើត និងដាក់ឱ្យអនុវត្ត រួមមានជាអាទិ៍ នីតិវិធីសម្រាប់ការរៀបចំកិច្ចប្រជុំ និងវេទិកាពិគ្រោះយោបល់សាធារណៈរបស់ក្រុមប្រឹក្សា នីតិវិធីដាក់ចេញសេចក្តីសម្រេចចិត្តនានារបស់ក្រុមប្រឹក្សា (ដីកា និងសេចក្តីសម្រេចនានា) និងនីតិវិធីគ្រប់គ្រងកិច្ចការរដ្ឋបាល។ល។ ជាមួយគ្នានេះ ប្រព័ន្ធគ្រប់គ្រងនានារបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក៏ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ដែលរួមមានប្រព័ន្ធកសាងផែនការ ប្រព័ន្ធផ្ទេរមូលនិធិ និងគ្រប់គ្រងហិរញ្ញវត្ថុ ប្រព័ន្ធគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្ស ប្រព័ន្ធទំនាក់ទំនងអន្តររដ្ឋបាល ប្រព័ន្ធត្រួតពិនិត្យនីត្យានុកូលភាព និងគាំទ្របច្ចេកទេស និងប្រព័ន្ធសម្រុះសម្រួលវិវាទនៅមូលដ្ឋានជាដើម។ ប្រព័ន្ធគ្រប់គ្រងទាំងនោះ រួមមានទាំងប្រព័ន្ធគ្រប់គ្រងនៅថ្នាក់ឃុំ សង្កាត់ក៏ត្រូវបានកែលម្អជាបណ្តើរៗ។
- ការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងនីតិវិធីអនុវត្តការងាររបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក៏បានពង្រឹងនូវខ្សែគណនេយ្យភាពតាមបែបប្រជាធិបតេយ្យរវាង

ថ្នាក់រដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ព្រមទាំងបានពង្រឹងនូវយន្តការត្រួតពិនិត្យនីត្យានុកូលភាព និងការគាំទ្រផ្នែកបច្ចេកទេសដល់រដ្ឋបាលឃុំ សង្កាត់ផងដែរ។ ប្រការនេះបានធានាឱ្យការងារកំណែទម្រង់នៅថ្នាក់ឃុំ សង្កាត់កាន់តែមានការរីកចម្រើនទៅមុខ និងធានាដល់ការលើកកម្ពស់ប្រសិទ្ធភាពពីអាណត្តិមួយទៅអាណត្តិមួយទៀតនៃក្រុមប្រឹក្សាប្រឹក្សាឃុំ សង្កាត់ ដែលក្នុងនោះ ក្នុងអាណត្តិទី១មានសមាជិកក្រុមប្រឹក្សាចំនួន១១.២៦១រូប អាណត្តិទី២មានសមាជិកក្រុមប្រឹក្សាចំនួន១១.៣៥៣រូប អាណត្តិទី៣មានសមាជិកក្រុមប្រឹក្សាចំនួន១១.៤៥៩ រូប និងអាណត្តិទី៤នេះមានសមាជិកក្រុមប្រឹក្សាចំនួន១១.៥៧២រូប ត្រូវបានបោះឆ្នោតជ្រើសរើសដោយផ្ទាល់ពីប្រជាពលរដ្ឋ បានចូលកាន់ដំណែងដើម្បីអនុវត្តការងារតាមមុខងារ និងតួនាទីដែលបានកំណត់ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានក្នុងការដោះស្រាយបញ្ហាប្រឈម និងឆ្លើយតបទៅនឹងតម្រូវការនានារបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

- គោលការណ៍នានាសម្រាប់ការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គម និងយុទ្ធសាស្ត្រស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រង និងធ្វើសេចក្តីសម្រេចចិត្តនៅរដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវបានបញ្ជ្រាបទៅក្នុងនីតិវិធីអនុវត្តការងារនិងប្រព័ន្ធគ្រប់គ្រងនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងកំពុងត្រូវបានយកចិត្តទុកដាក់អនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។
- ផែនការយុទ្ធសាស្ត្រ និងកម្មវិធីស្តីពីការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិក៏ត្រូវបានរៀបចំ និងអនុវត្តក្នុងភាពជាដៃគូយ៉ាងជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិលនានា ដើម្បីផ្តល់នូវព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងការអនុវត្តការងារការប្រើប្រាស់ថវិកា ការផ្តល់សេវា និងការអនុវត្តគម្រោងនានារបស់រដ្ឋបាលឃុំ សង្កាត់ និងអង្គភាពជំនាញនានានៅតាមមូលដ្ឋាន (សេវាអប់រំ និងសុខភាព) ព្រមទាំងដើម្បីបង្កលក្ខណៈឱ្យមានការចូលរួមតាមដានត្រួតពិនិត្យ និងផ្តល់យោបល់ពីប្រជាពលរដ្ឋលើការអនុវត្តការងាររបស់រដ្ឋបាលឃុំ សង្កាត់ និងការផ្តល់សេវារបស់អង្គភាពជំនាញទាំងនោះផងដែរ។ ការងារនេះបានអនុវត្តនៅខេត្តគោលដៅចំនួន១៨ ដែលមានស្រុកគោលដៅចំនួន៩៨ ដោយផ្តោតលើការអនុវត្តការងាររបស់រដ្ឋបាលឃុំចំនួន៧៣១ សេវាមណ្ឌលសុខភាពចំនួន៥៧០ និងសាលាបឋមសិក្សាចំនួន១.៣៩៩។ ប្រជាពលរដ្ឋប្រមាណជាង១លាននាក់បានចូលរួមនៅក្នុងកម្មវិធីការងារគណនេយ្យភាពសង្គមនេះ។
- ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តនៅតាមស្រុកគោលដៅចំនួន១០៤ក្រុង ស្រុក ដើម្បីបង្កលក្ខណៈងាយស្រួលដល់រដ្ឋបាលក្រុង ស្រុកក្នុងការប្រមូល និងគ្រប់គ្រងទិន្នន័យព័ត៌មានចាំបាច់នានាសម្រាប់ធ្វើជាមូលដ្ឋានក្នុងការធ្វើសេចក្តីសម្រេចចិត្ត ក៏ដូចសម្រាប់ធ្វើការវិភាគស្ថានភាពនានាក្នុងការរៀបចំផែនការ កម្មវិធីអភិវឌ្ឍ និងការគ្រប់គ្រង ការតាមដានត្រួតពិនិត្យការអនុវត្តការងាររបស់ខ្លួនផងដែរ។

ជារួម រហូតមកដល់បច្ចុប្បន្ននេះ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលជាមូលដ្ឋានគ្រឹះនៃកំណែទម្រង់តាមគោលការណ៍នៃរដ្ឋបាលឯកភាព និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ដោយមានការកែសម្រួលជាបណ្តើរៗ ដើម្បីធានាដល់ការលើក

កម្ពស់នូវស្វ័យភាព ការទទួលខុសត្រូវ និរន្តរភាព និងការបង្កើនប្រសិទ្ធភាពការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈ និងកិច្ចអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយតម្លាភាព គណនេយ្យភាព និងមានការចូលរួមពីប្រជាពលរដ្ឋ សហគមន៍មូលដ្ឋាន អង្គការសង្គមស៊ីវិល និងផ្នែកឯកជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**៩. បញ្ហាប្រឈម**

ទោះបីមានវឌ្ឍនភាពជាច្រើនពាក់ព័ន្ធនឹងការរៀបចំឡើងវិញនូវស្ថាប័ននៃរដ្ឋបាលថ្នាក់ក្រោមជាតិដូចបានរៀបរាប់ខាងលើក៏ដោយ ក៏នៅមានបញ្ហាប្រឈមមួយចំនួនពាក់ព័ន្ធនឹងរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងការអនុវត្តតាមគោលការណ៍នៃអភិបាលកិច្ចល្អមួយចំនួនដែលត្រូវបន្តដោះស្រាយ ដែលក្នុងនោះរួមមាន៖

- រចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅពុំទាន់ឆ្លើយតបទៅនឹងការវិវឌ្ឍ និងការរីកចម្រើនផ្នែកសេដ្ឋកិច្ច និងសង្គមនៅតាមតំបន់ជាក់លាក់នានា និងពុំទាន់បានកំណត់ និងបែងចែកឱ្យបានច្បាស់លាស់នូវតួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះឱ្យស្របតាមប្រភេទ ឬចរិតលក្ខណៈផ្សេងៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះឡើយ ជាពិសេសការរៀបចំឱ្យបានជាក់លាក់នូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងរវាងទីក្រុងធំៗ ដូចជារាជធានីភ្នំពេញ និងទីក្រុងក្រៅពីរាជធានីភ្នំពេញ និងទីប្រជុំជនដែលកំពុងមានការកើនឡើងយ៉ាងលឿន និងកំពុងជួបប្រទះបញ្ហាប្រឈមនានាកាន់តែច្រើនឡើងៗពាក់ព័ន្ធនឹងការរៀបចំប្លង់គោល ប្លង់ប្រើប្រាស់ដីធ្លី ការងារសណ្តាប់ធ្នាប់សាធារណៈ អនាម័យនៅទីក្រុង ទីប្រជុំជនជាដើម។ ព្រមជាមួយគ្នានេះ ក៏ទាមទារត្រូវមានការសិក្សា និងការបន្តកែសម្រួលរចនាសម្ព័ន្ធនៃរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីកំណត់ឱ្យបានច្បាស់លាស់អំពីតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលខេត្តធ្វើជាតំណាងឱ្យរាជរដ្ឋាភិបាលក្នុងការតាមដានត្រួតពិនិត្យ ការផ្តល់ការគាំទ្របច្ចេកទេស និងការអភិវឌ្ឍសមត្ថភាព រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ដែលជារដ្ឋបាលមូលដ្ឋាន មានតួនាទីសំខាន់ក្នុងការផ្តល់សេវាសាធារណៈ និងអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានដោយផ្ទាល់ជាមួយប្រជាពលរដ្ឋ។
- ប្រព័ន្ធគ្រប់គ្រងនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅពុំទាន់មានលក្ខណៈពេញលេញ ដើម្បីធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពបំពេញគណនេយ្យភាពច្បាស់លាស់ ក្នុងការផ្តល់សេវាចាំបាច់នានាដោយផ្ទាល់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ដោយសារសេវាទាំងនោះភាគច្រើនស្ថិតនៅក្រោមការទទួលខុសត្រូវ និងការអនុវត្តរបស់មន្ទីរ អង្គភាពខ្សែបណ្តោយរបស់ក្រសួង ស្ថាប័នជំនាញនៅឡើយ។
- ការចូលរួម និងការផ្តល់យោបល់របស់ប្រជាពលរដ្ឋក្នុងកិច្ចដំណើរការធ្វើសេចក្តីសម្រេចចិត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅមានកម្រិត ដោយសារការរៀបចំយន្តការ និងនីតិវិធីនានាពុំទាន់មានលក្ខណៈសមស្រប ហើយទម្លាប់ និងឥរិយាបថនៃការចូលរួមនៅមិនទាន់មានការផ្លាស់ប្តូរឱ្យបានជ្រាលជ្រៅទាំងកិច្ចដំណើរការនៃការរៀបចំឱ្យមានការចូលរួម និងការផ្តល់យោបល់ និងដោយសារជំនឿជឿជាក់របស់ប្រជាពលរដ្ឋមកលើលទ្ធភាពដោះស្រាយបញ្ហាដ៏មានកម្រិតរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

- ទោះបីមានការដាក់ចេញនូវគោលការណ៍ លិខិតបទដ្ឋានគតិយុត្ត និងកម្មវិធីដើម្បីលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គមក៏ដោយ ក៏ប៉ុន្តែកិច្ចការនេះបានអនុវត្តភាគច្រើនតែលើបញ្ហាយេនឌ័រ ដោយពុំបានផ្តោតការយកចិត្តទុកដាក់ឱ្យបានទូលំទូលាយ និងស៊ីជម្រៅទៅលើបញ្ហាប្រឈមពាក់ព័ន្ធនឹងយុវជន ជនពិការ ចាស់ជរា ជនជាតិដើមភាគតិច និងក្រុមជនងាយរងគ្រោះផ្សេងៗទៀត។
- ការលើកកម្ពស់តម្លាភាព តាមរយៈការអនុវត្តការងារគណនេយ្យភាពសង្គមដែលបានអនុវត្តតែនៅក្នុងវិស័យមួយចំនួន និងនៅឃុំគោលដៅមួយចំនួនតែប៉ុណ្ណោះ។ ជាមួយគ្នានេះដែរការងារនេះនៅពុំទាន់បានធ្វើសមាហរណកម្មពេញលេញទៅក្នុងប្រព័ន្ធកសាងផែនការ និងការរៀបចំថវិការបស់រដ្ឋបាលឃុំ និងអង្គភាពពាក់ព័ន្ធនានា (សាលារៀន និងមណ្ឌលសុខភាព) នៅឡើយ។
- យន្តការអធិការកិច្ចលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ នៅពុំទាន់ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តប្រកបដោយសុខដុមនីយកម្មរវាងក្រសួង ស្ថាប័នមានសមត្ថកិច្ចនានានៅឡើយ។ ស្ថានភាពនេះបានធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិទទួលនូវសម្ពាធ និងមានបន្ទុកការងារយ៉ាងច្រើនក្នុងការរៀបចំទទួល និងការចូលរួមកិច្ចដំណើរការធ្វើអធិការកិច្ចរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ចនានាជាច្រើន។ ប្រការនេះតម្រូវឱ្យមានការសិក្សា និងរៀបចំយន្តការធ្វើអធិការកិច្ច ឬការវាយតម្លៃប្រចាំឆ្នាំលើការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជានាដល់ការលើកទឹកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកតាមលទ្ធផលនៃការបំពេញការងាររបស់ខ្លួនបានល្អតាមស្តង់ដា និងតាមសូចនាករដែលបានកំណត់។

## ៣. ការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានតម្រូវឱ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានបុគ្គលិករបស់ខ្លួន ប្រកបដោយគុណភាព សមត្ថភាពទាំងក្នុងផ្នែកអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងវិមជ្ឈការ និងបច្ចេកទេសជំនាញក្នុងការអភិវឌ្ឍមូលដ្ឋាន សំដៅជានាឱ្យបុគ្គលិកទាំងនោះបំពេញការងារនានាប្រកបដោយប្រសិទ្ធភាពតាមការសម្រេចរបស់ក្រុមប្រឹក្សា និងមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា។ ដើម្បីជានាដល់ការសម្រេចបាននូវគោលបំណងនេះ តម្រូវឱ្យមានការរៀបចំលក្ខន្តិកៈដោយឡែកមួយសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងការរៀបចំការផ្ទេរបុគ្គលិកទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដោយផ្សារភ្ជាប់ជាមួយនឹងកិច្ចដំណើរការផ្ទេរមុខងារ ដែលកិច្ចដំណើរការនេះមានលក្ខណៈសាំញ៉ាំ ស្មុគស្មាញ ទាមទារឱ្យមានការរៀបចំអនុវត្តដោយប្រុងប្រយ័ត្ន តាមជំហានៗដ៏សមស្រប ដែលជានាមិនឱ្យមានការបង្កើននូវចំនួនមន្ត្រីសាធារណៈទូទាំងប្រទេស។ ព្រមជាមួយនេះ ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិក៏តម្រូវឱ្យរៀបចំជាប្រព័ន្ធអចិន្ត្រៃយ៍ក្នុងការវាយតម្លៃ ដើម្បីរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្សរយៈពេលខ្លី និងរយៈពេលពីមធ្យមទៅរយៈពេលវែង ព្រមទាំងការកំណត់ និងការទទួលខុសត្រូវរវាងថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុង

ការងារនេះស្របតាមតម្រូវការនៃការកែទម្រង់ និងតម្រូវការនៃការផ្តល់សេវា និងការអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។

ពាក់ព័ន្ធនឹងការរៀបចំបង្កើតប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិនេះ កម្មវិធីជាតិបានកំណត់នូវកិច្ចការជាអាទិភាពដែលត្រូវអនុវត្តតាមដំណាក់នីមួយៗរួមមាន៖

១) ការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការគ្រប់គ្រងបុគ្គលិក និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
២) ការរៀបចំផ្ទេរបុគ្គលិកភ្ជាប់ជាមួយនឹងការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
៣) ការបង្កើតកម្មវិធីនានាសម្រាប់ការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និង
៤) ការបញ្ជ្រាបការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គមទៅក្នុងប្រព័ន្ធគ្រប់គ្រងបុគ្គលិកនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ក. វឌ្ឍនភាព**

ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ និងក្រសួងស្ថាប័នពាក់ព័ន្ធនានា រហូតមកដល់ពេលបច្ចុប្បន្ននេះ មានសមិទ្ធផលជាច្រើនពាក់ព័ន្ធការរៀបចំប្រព័ន្ធគ្រប់គ្រងបុគ្គលិក និងការអភិវឌ្ឍធនធានមនុស្សតាមបែបវិមជ្ឈការត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ដែលក្នុងនោះរួមមាន៖

- លិខិតបទដ្ឋានគតិយុត្តសំខាន់ៗជាច្រើនពាក់ព័ន្ធនឹងការរៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងបុគ្គលិក និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្ទេរសិទ្ធិអំណាចជាបណ្តើៗទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងបុគ្គលិកដែលបំពេញការងារនៅថ្នាក់ក្រោមជាតិក្នុងដំណាក់កាលអន្តរកាល ព្រមទាំងរៀបចំឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានបុគ្គលិករបស់ខ្លួន និងមានប្រព័ន្ធគ្រប់គ្រងបុគ្គលិកទាំងនោះក្នុងលក្ខណៈជាអចិន្ត្រៃយ៍ផងដែរ។ លិខិតបទដ្ឋានគតិយុត្តសំខាន់ដែលបានរៀបចំ និងដាក់ឱ្យអនុវត្ត រួមមានជាអាទិ៍៖ ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដើម្បីអនុញ្ញាតឱ្យធ្វើប្រតិភូកម្មអំណាចទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលដែលបំពេញ ការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ អនុក្រឹត្យស្តីពីការធ្វើប្រតិភូកម្មអំណាចទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងបុគ្គលិកដែលបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គោលនយោបាយ ស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្តល់គោលការណ៍តម្រង់ទិសសម្រាប់ការរៀបចំប្រព័ន្ធគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈជាអចិន្ត្រៃយ៍ ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិដែលកំណត់អំពីប្រព័ន្ធ គោលការណ៍ និងនីតិវិធីសម្រាប់គ្រប់គ្រងបុគ្គលិកផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងសេចក្តីណែនាំនានាស្តីពីនីតិវិធីលម្អិតនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ទាំងក្នុងបែបផែននៃការធ្វើប្រតិភូកម្ម និងការប្រគល់អំណាច។ ជាមួយគ្នានេះ ផែនការយុទ្ធសាស្ត្រក្នុងការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោម

ជាតិ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តផងដែរ។

- មន្ត្រីរាជការដែលធ្លាប់បំពេញការងារនៅតាមសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទូទាំងប្រទេសចំនួនប្រមាណជាង៨.០០០នាក់ ត្រូវបានធ្វើសមាហរណកម្មចូលមកក្នុងរចនាសម្ព័ន្ធនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលត្រូវបានកែសម្រួលជាថ្មី។
- ការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត និងអំពីក្របខ័ណ្ឌនៃការអនុវត្តតាមប្រព័ន្ធនិងនីតិវិធីអនុវត្តការងារនានាត្រូវបានផ្តល់ជាប្រចាំ តាមរយៈវគ្គបណ្តុះបណ្តាលខ្លីៗចំនួនប្រមាណជាង២៥០វគ្គ ដោយមានសមាជិកក្រុមប្រឹក្សា និងបុគ្គលិកនៃរដ្ឋបាលថ្នាក់ក្រោមជាតិចូលរួមប្រមាណ២៨៤.៥៩៥នាក់ និងតាមរយៈសិក្ខាសាលា និងការហ្វឹកហាត់ការងារនៅតាមកន្លែងជាក់ស្តែងនីមួយៗ។ ដើម្បីរៀបចំនូវប្រព័ន្ធ និងយន្តការអចិន្ត្រៃយ៍មួយសម្រាប់ការផ្តល់សេវាអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលបានដាក់ចេញអនុក្រឹត្យស្តីពីការរៀបចំបង្កើត និងការប្រព្រឹត្តទៅសាលាជាតិរដ្ឋបាលមូលដ្ឋាន ដែលកំពុងត្រូវបានអនុវត្ត។

**៦. បញ្ហាប្រឈម**

ទោះបីមានវឌ្ឍនភាពជាច្រើនពាក់ព័ន្ធនឹងការរៀបចំប្រព័ន្ធ និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិដូចបានរៀបរាប់ខាងលើក៏ដោយ ក៏នៅមានបញ្ហាប្រឈមសំខាន់មួយចំនួនដែលត្រូវបន្តដោះស្រាយ ដែលក្នុងនោះរួមមាន ៖

- ភាពយឺតយ៉ាវនៃការរៀបចំ និងការដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តចាំបាច់នានាក្នុងការបង្កើតប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលធានាដល់ការផ្តល់ស្វ័យភាពសមស្របដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងបុគ្គលិករបស់ខ្លួន និងដែលជំរុញលើកទឹកចិត្តឱ្យមន្ត្រីសាធារណៈស្ម័គ្រចិត្តទៅបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាបញ្ហាប្រឈមជាគន្លឹះនៃការផ្ទេរ និងការជ្រើសរើសបុគ្គលិកដែលមានសមត្ថភាពឱ្យទៅបម្រើការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ប្រការនោះតម្រូវឱ្យបន្តការយកចិត្តទុកដាក់ពន្លឿនការរៀបចំបញ្ចប់ និងការដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការអនុវត្តលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។ ព្រមជាមួយគ្នានេះ ទាមទារឱ្យមានការសិក្សារៀបចំនូវគោលនយោបាយ និងប្រព័ន្ធលើកទឹកចិត្ត រួមទាំងឋានន្តរស័ក្តិរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅជំរុញលើកទឹកចិត្តដល់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសនៅតំបន់ជនបទ និងសំដៅស្រូបទាញបាននូវធនធានមនុស្សដែលមានគុណភាព សមត្ថភាព សម្រាប់បម្រើការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិនាពេលកន្លងមកតាមរយៈវគ្គបណ្តុះបណ្តាលសិក្ខាសាលា និងការហ្វឹកហាត់ការងារភាគច្រើនផ្តោតតែទៅលើក្របខ័ណ្ឌច្បាប់លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអនុវត្តនូវប្រព័ន្ធគ្រប់គ្រងថ្មីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយពុំបានផ្តោតទៅលើការអភិវឌ្ឍសមត្ថភាពលើជំនាញជាក់លាក់ដែលត្រូវការចាំបាច់សម្រាប់ការបង្កើតគំនិតផ្តួចផ្តើមក្នុងការដឹកនាំ ការរៀបចំ ការគ្រប់គ្រង ការចាត់ចែងការផ្តល់សេវាសាធារណៈ

និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានជាក់ស្តែងនៅឡើយ។

- ការបណ្តុះបណ្តាល កសាងសមត្ថភាពនានាដល់រដ្ឋបាលថ្នាក់ក្រោមជាតិដែលរៀបចំឡើងដោយក្រសួង ស្ថាប័ននានាពុំទាន់មានការសម្របសម្រួលគ្នាឱ្យបានល្អ និងពុំទាន់មានស្តង់ដាគ្រប់គ្រាន់ ដើម្បីធានាគុណភាពនៃការអភិវឌ្ឍសមត្ថភាពទាំងនោះនៅឡើយ។

## ៤. ការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

ការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាសមាសភាគស្នូលនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ការផ្ទេរមុខងារ ជាកិច្ចដំណើរការនៃការផ្ទេរការធ្វើសេចក្តីសម្រេចចិត្ត និងការទទួលខុសត្រូវក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាននានាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដែលនៅកៀកជិតប្រជាពលរដ្ឋ ដើម្បីធានាដល់ការលើកកម្ពស់គុណភាពនៃការផ្តល់សេវា និងការអភិវឌ្ឍទាំងនោះឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ទៅតាមជម្រើសផ្សេងៗគ្នាដោយផ្អែកតាមស្ថានភាព និងតម្រូវការជាក់ស្តែងនៃមូលដ្ឋាននីមួយៗ។ ការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធ្វើឡើងក្នុងលក្ខណៈជាប្រព័ន្ធ មានសនិទានភាពច្បាស់លាស់ផ្អែកតាមដែនសមត្ថកិច្ចនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗទៅតាមគោលការណ៍ "**សាប់ស៊ីឌីយ៉ារិធី**" មានន័យថា មុខងារណាដែលសមស្រប និងអាចអនុវត្តមានប្រសិទ្ធភាពជាងដោយរដ្ឋបាលថ្នាក់ក្រោមជាតិណាមួយ មុខងារនោះត្រូវតែបានជំរុញ និងលើកទឹកចិត្តក្នុងការផ្ទេរឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិសមស្របទាំងនោះ។ ទន្ទឹមនឹងនេះ ក្នុងការផ្ទេរមុខងារ គឺមិនគួរផ្ទេរមុខងារណាដែលក្រសួង ស្ថាប័នមានការលំបាកស្មុគស្មាញក្នុងការអនុវត្តទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនោះឡើយ។ ស្របពេលជាមួយនេះ ការផ្ទេរមុខងារត្រូវផ្សារភ្ជាប់ជាមួយនឹងការផ្ទេរធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងមធ្យោបាយនានា ព្រមទាំងសិទ្ធិអំណាច និងការទទួលខុសត្រូវលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារទាំងនោះផងដែរ។ ផ្អែកតាមបទពិសោធន៍នៃការអនុវត្តមុខងារជាជម្រើស ឬមុខងារជាអាណត្តិទូទៅ ដែលរដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលក្រុង ស្រុកបានអនុវត្តក្នុងមួយឆ្នាំៗប្រមាណជាង១.៨០០គម្រោង ដែលគ្របដណ្តប់លើគ្រប់វិស័យដើម្បីឆ្លើយតបតម្រូវការចាំបាច់ជាអាទិភាពបំផុតនៅតាមមូលដ្ឋាននីមួយៗ ហើយដែលត្រូវបានសាទរ និងមានការពេញចិត្តពីប្រជាពលរដ្ឋ និងសហគមន៍នានានៅមូលដ្ឋាន គឺជាអំណះអំណាងអំពីលទ្ធភាព និងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង និងចាត់ចែងមុខងារនានាកាន់តែច្រើនឡើងថែមទៀត ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការជាក់ស្តែងតាមមូលដ្ឋានដែលមានការកើនឡើងជា រៀងរាល់ថ្ងៃ ស្របតាមការវិវឌ្ឍរីកចម្រើនរបស់សង្គម។

លើមូលដ្ឋាននេះ ដើម្បីធានាឱ្យកិច្ចដំណើរការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ អាចប្រព្រឹត្តទៅដោយជោគជ័យ កម្មវិធីជាតិបានកំណត់នូវកិច្ចការជាអាទិភាពដែលត្រូវអនុវត្តតាមដំណាក់កាលនីមួយៗ រួមមាន ៖

១) ការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចដំណើរការផ្ទេរមុខងារ

២) ការកំណត់នូវមុខងារសមស្រប និងធនធានជាក់លាក់ដែលត្រូវផ្ទេរទៅរដ្ឋបាលថ្នាក់ក្រោមជាតិ

៣) ការផ្ទេរមុខងារដោយភ្ជាប់ជាមួយនឹងធនធានចាំបាច់នានាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

៤) ការរៀបចំគម្រោង និងកម្មវិធីនានាដើម្បីលើកកម្ពស់ការផ្តល់សេវាសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ក. វឌ្ឍនភាព**

ដោយមានការដឹកនាំ សម្របសម្រួលរបស់ គ.ជ.អ.ប និងការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធនានា បានជំរុញឱ្យកិច្ចដំណើរការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្តជាបណ្តើរៗ រួមជាមួយនឹងបញ្ហាប្រឈមនានាដែលត្រូវបន្តជំរុញ និងដោះស្រាយបន្ថែមទៀត។ វឌ្ឍនភាពពាក់ព័ន្ធនឹងការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន៖

- លិខិតបទដ្ឋានគតិយុត្តសំខាន់ៗពាក់ព័ន្ធនឹងកិច្ចដំណើរការផ្ទេរមុខងារត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត រួមមានអនុក្រឹត្យស្តីពីកិច្ចដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំបញ្ជីវិភាគមុខងារ និងសេចក្តីណែនាំស្តីពីការពិនិត្យមើលមុខងារឡើងវិញដើម្បីកំណត់មុខងារសមស្រប និងធនធានជាក់លាក់ដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។
- ផ្អែកតាមលិខិតបទដ្ឋានគតិយុត្តទាំងនេះ ក្រសួង ស្ថាប័នចំនួន១៤ បានរៀបចំកិច្ចដំណើរការផ្ទេរមុខងារ និងធនធានជាបណ្តើរៗទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលក្នុងនោះរួមមាន ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងអភិវឌ្ឍជនបទ ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា ក្រសួងបរិស្ថាន ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងទេសចរណ៍ ក្រសួងពាណិជ្ជកម្ម ក្រសួងរ៉ែ និងថាមពល ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។
- ក្នុងចំណោមក្រសួងទាំង១៤ដែលបានរៀបចំអនុវត្តកិច្ចដំណើរការផ្ទេរមុខងារ រហូតមកដល់ពេលនេះមានក្រសួងចំនួន៧ បានឈានទៅផ្ទេរមុខងារចំនួន១៨ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលក្នុងនោះរួមមាន៖
  - ✓ ក្រសួងបរិស្ថានបានផ្ទេរមុខងារចំនួន៦៖ មុខងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជនត្រូវបានប្រគល់ក្នុងលក្ខណៈកាតព្វកិច្ចទៅរដ្ឋបាលរាជធានី ក្រុង ស្រុក មុខងារគ្រប់គ្រងតំបន់ការពារធម្មជាតិត្រូវបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលក្រុង ស្រុកដែលមានតំបន់ការពារធម្មជាតិ មុខងារគ្រប់គ្រងសហគមន៍ក្នុងតំបន់ការពារធម្មជាតិត្រូវបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលឃុំដែលមានសហគមន៍តំបន់ការពារធម្មជាតិ មុខងារអប់រំបរិស្ថាន ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុត្រូវបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលរាជធានី ខេត្ត និងមុខងារគ្រប់គ្រងប្រព័ន្ធលូនិងអាងប្រព្រឹត្តកម្មទឹកកខ្វក់ត្រូវបានប្រគល់ក្នុងលក្ខណៈជាកាតព្វកិច្ចទៅឱ្យរដ្ឋបាល ក្រុង ស្រុក ខណ្ឌ។
  - ✓ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានផ្ទេរមុខងារចំនួន៣៖ មុខងារគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋត្រូវបានប្រគល់ក្នុងលក្ខណៈជាកាតព្វកិច្ចទៅឱ្យរដ្ឋបាល

រាជធានី ខេត្ត មុខងារត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការសង្គមស៊ីវិលត្រូវបានប្រគល់ជាលក្ខណៈកាតព្វកិច្ចទៅឱ្យរដ្ឋបាលក្រុង ស្រុក និងមុខងារគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះក្នុងសហគមន៍ត្រូវបានប្រគល់ជាលក្ខណៈកាតព្វកិច្ចទៅឱ្យរដ្ឋបាលឃុំ សង្កាត់។

- ✓ ក្រសួងអភិវឌ្ឍន៍ជនបទបានផ្ទេរមុខងារចំនួន៣៖ មុខងារជួសជុលថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ជនបទត្រូវបានធ្វើប្រតិភូកម្មក្នុងលក្ខណៈជាការសាកល្បងទៅឱ្យរដ្ឋបាលស្រុកគោលដៅចំនួន១១ មុខងារផ្តល់សេវាអនាម័យជនបទត្រូវបានធ្វើប្រតិភូកម្មក្នុងលក្ខណៈជាការសាកល្បងទៅឱ្យរដ្ឋបាលស្រុកគោលដៅចំនួន១៥ និងមុខងារថែទាំផ្លូវជនបទត្រូវបានធ្វើប្រតិភូកម្មក្នុងលក្ខណៈជាការសាកល្បងទៅឱ្យរដ្ឋបាលស្រុកគោលដៅចំនួន០៤។
- ✓ ក្រសួងរ៉ែនិងថាមពលបានផ្ទេរមុខងារចំនួន១៖ មុខងារផ្តល់អាជ្ញាប័ណ្ណធនធានរ៉ែសម្រាប់ប្រតិបត្តិការរ៉ែដែលមានលក្ខណៈជាសិប្បកម្មខ្នាតតូចត្រូវបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលរាជ ធានី ខេត្ត។
- ✓ ក្រសួងទេសចរណ៍បានផ្ទេរមុខងារចំនួន១៖ មុខងារគ្រប់គ្រងមណ្ឌលកម្សាន្តមនុស្សពេញវ័យត្រូវបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលរាជធានី ខេត្ត។
- ✓ ក្រសួងឧស្សាហកម្ម និងសិប្បកម្មបានផ្ទេរមុខងារចំនួន២៖ មុខងារគ្រប់គ្រងការបង្កើត និងចុះបញ្ជីរោងចក្រដែលមានដើមទុនក្រោម២លានដុល្លាត្រូវបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលរាជធានី ខេត្ត និងមុខងារចុះបញ្ជីសហគ្រាស សិប្បកម្មដែលមានដើមទុនក្រោម ៥.០០០ដុល្លា ត្រូវបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលក្រុង ស្រុក។
- ✓ ក្រសួងអប់រំ យុវជន និងកីឡាបានផ្ទេរមុខងារចំនួន៤៖ នៅឆ្នាំ២០១៦ រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យដើម្បីផ្ទេរមុខងារគ្រប់គ្រងការអប់រំកុមារតូច មុខងារគ្រប់គ្រងការអប់រំបឋមសិក្សា មុខងារគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធត្រូវបានប្រគល់ក្នុងលក្ខណៈជាកាតព្វកិច្ចទៅឱ្យរដ្ឋបាលក្រុង ស្រុក និងមុខងារគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ត្រូវបានប្រគល់ក្នុងលក្ខណៈជាជម្រើសទៅឱ្យរដ្ឋបាលឃុំ សង្កាត់។ ប៉ុន្តែបច្ចុប្បន្ន រដ្ឋបាលក្រុង ស្រុកទាំងនោះពុំទាន់មានលទ្ធភាពក្នុងការចាប់ផ្តើមគ្រប់គ្រង ចាត់ចែង អនុវត្តមុខងារដែលបានផ្ទេរទាំងនោះនៅឡើយ។

- ក្រសួងចំនួន៧ទៀតបាន និងកំពុងស្ថិតក្នុងដំណាក់កាលនៃការកំណត់នូវមុខងារដែលនឹងត្រូវផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិចាប់ពីឆ្នាំ២០១៨តទៅ។
- ទន្ទឹមគ្នានេះ ដើម្បីធានាដល់ការពន្លឿនកិច្ចដំណើរការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលបានសម្រេចឱ្យរៀបចំផ្ទេរមុខងារសំខាន់ៗចំនួន២៨ ដែលស្ថិតក្នុងវិស័យចំនួន៧ គឺវិស័យសុខាភិបាល សាធារណការនិងដឹកជញ្ជូន បរិស្ថាន និងកសិកម្ម អភិវឌ្ឍជនបទ សង្គមកិច្ច ទេសចរណ៍ និងធនធានទឹក ចាប់ពីឆ្នាំ២០១៨តទៅ។
- ពាក់ព័ន្ធនឹងការផ្ទេរមុខងារផ្តល់សេវារដ្ឋបាល ក្រសួង ស្ថាប័នចំនួន១០បានធ្វើប្រតិភូកម្មមុខងារផ្តល់សេវារដ្ឋបាលចំនួន១២៥ប្រភេទទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិលើការផ្តល់សេវារដ្ឋបាលទាំងនោះជូនប្រជាពលរដ្ឋតាមរយៈការិយាល័យច្រកចេញចូលតែមួយ។ រហូតមកដល់ពេល

នេះ ការិយាល័យច្រកចេញចូលតែមួយត្រូវបានបង្កើត និងដាក់ឱ្យដំណើរការនៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន៥២ ដើម្បីផ្តល់សេវារដ្ឋបាលដែលបានធ្វើប្រតិភូកម្ម។ គិតត្រឹមឆ្នាំ២០១៧ មានប្រជាពលរដ្ឋចំនួនប្រមាណ២.១៤៣.០៦៨នាក់ បានមកទទួលសេវានៅការិយាល័យច្រកចេញចូលតែមួយទាំងនោះ ហើយការិយាល័យច្រកចេញចូលតែមួយបានប្រមូលចំណូលពីការផ្តល់សេវារដ្ឋបាលទាំងនេះចំនួនប្រមាណជាង១៤លានដុល្លា។ ផ្អែកលើបទពិសោធន៍នេះ រាជរដ្ឋាភិបាលសម្រេចឱ្យបង្កើតអង្គភាពច្រកចេញចូលតែមួយនៅរដ្ឋបាលរាជធានី ខេត្តដែលកិច្ចការនេះកំពុងត្រូវបានរៀបចំ និងចាប់ផ្តើមដំណើរការចាប់ពីឆ្នាំ២០១៨នេះតទៅ ដើម្បីផ្តល់សេវារដ្ឋបាលចំនួនប្រមាណជិត១០០ប្រភេទជូនប្រជាពលរដ្ឋ។

**៩. បញ្ហាប្រឈម**

ទោះបីមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងកិច្ចដំណើរការរៀបចំផ្ទេរមុខងារក៏ដោយ ក៏នៅមានបញ្ហាប្រឈមជាគន្លឹះជាច្រើនដែលត្រូវដោះស្រាយ ក្នុងនោះរួមមាន៖

- ជារួម យើងបានប្រើប្រាស់ពេលវេលាជាងមួយទសវត្សរ៍កន្លះនៅថ្នាក់ឃុំ សង្កាត់ និងជិតមួយទសវត្សរ៍នៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក្នុងការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធ និងនីតិបំពេញការងារ រួមទាំងការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរហូតមកដល់បច្ចុប្បន្ន រដ្ឋបាលថ្នាក់ក្រោមជាតិបានក្លាយជាស្ថាប័នអភិបាលកិច្ចដែលអាចមានលទ្ធភាពជាមូលដ្ឋានក្នុងការផ្តល់សេវា និងអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយតម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងអាចជឿជាក់បានពីប្រជាពលរដ្ឋ និងសហគមន៍នានានៅមូលដ្ឋាន។ ប៉ុន្តែរហូតមកដល់ពេលនេះ រដ្ឋបាលថ្នាក់ក្រោមជាតិនៅពុំទាន់បានទទួលការផ្ទេរមុខងារ និងធនធានសមស្របសម្រាប់ឆ្លើយតបសេចក្តីត្រូវការចាំបាច់នៃជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋនៅឡើយ។ ប្រការនេះ ទាមទារត្រូវពង្រឹងការប្តេជ្ញាចិត្តខាងនយោបាយប្រកបដោយការស្រុះស្រួលឯកភាពគ្នា ក្នុងចំណោមក្រសួង ស្ថាប័ននានាក្នុងការផ្ទេរមុខងារ និងធនធានសមស្របជាក់លាក់ និងជាប្រព័ន្ធទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីជំរុញកិច្ចដំណើរការកំណែទម្រង់នេះឱ្យបោះជំហានទៅមុខស្របតាមគោលការណ៍ដែលមានចែងក្នុងច្បាប់រៀបចំអង្គការ ហើយដែលត្រូវអនុវត្តនៅក្នុងដំណាក់កាលចុងក្រោយនៃកម្មវិធីជាតិ។
- ក្នុងដំណើរការផ្ទេរមុខងារក្នុងរយៈពេលកន្លងមក ក្រសួង ស្ថាប័នមួយចំនួននៅមានភាពស្ទាក់ស្ទើរ អល់អែកក្នុងដំណើរការនេះ។ ជាក់ស្តែងមុខងារក្នុងវិស័យមួយចំនួនត្រូវបានរៀបចំលិខិតបទដ្ឋានរួចរាល់សម្រាប់ការផ្ទេរ ក៏ប៉ុន្តែនៅមិនទាន់បានអនុវត្តជាក់ស្តែងនៅឡើយ។ មុខងារក្នុងវិស័យមួយចំនួនទៀតត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិរួចហើយ ប៉ុន្តែរដ្ឋបាលថ្នាក់ក្រោមជាតិនៅពុំទាន់មានលទ្ធភាពចាប់ផ្តើមអនុវត្តបាន ដោយសារមិនទាន់បានផ្ទេរធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ ឬបានផ្ទេរធនធានហិរញ្ញវត្ថុ ប៉ុន្តែមានចំនួនតិចតួចមិនសមស្របក្នុងការអនុវត្តមុខងារដែលបានផ្ទេរទាំងនោះ ហើយការផ្ទេរធនធានក៏មានភាពយឺតយ៉ាវថែមទៀត។ មុខងារក្នុងវិស័យមួយចំនួនត្រូវបានផ្ទេរ ក៏ប៉ុន្តែនៅមានការខ្វះខាតលិខិត

បទដ្ឋាន និងស្តង់ដាសម្រាប់អនុវត្តមុខងារដែលបានផ្ទេរទាំងនោះ។ ក្រសួង ស្ថាប័នមួយចំនួនបានផ្ទេរមុខងារដែលភ្ជាប់មកជាមួយនូវគោលការណ៍ បែបបទ និងនីតិវិធីសាំញ៉ាំ ស្មុគស្មាញ ដែលធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិលំបាកស្វែងយល់ក្នុងការអនុវត្ត។ ក្រសួង ស្ថាប័នមួយចំនួនទៀតពុំទាន់បានរៀបចំផែនការសកម្មភាព និងកម្មវិធីច្បាស់លាស់សម្រាប់គាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារដែលបានផ្ទេរនៅឡើយ។ ជារួម ការផ្ទេរមុខងារ និងធនធានក្នុងរយៈពេលកន្លងមកនៅពុំទាន់បានរៀបចំជាប្រព័ន្ធរួមមួយក្នុងការផ្ទេរធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស ការអភិវឌ្ឍសមត្ថភាព ការរៀបចំនីតិវិធី និងស្តង់ដាសម្រាប់ការអនុវត្ត ការរៀបចំប្រព័ន្ធគាំទ្រ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តមុខងារដែលបានផ្ទេរ ដែលបញ្ហាទាំងនេះទាមទារត្រូវធ្វើការពិនិត្យ និងរៀបចំឡើងវិញជាប្រព័ន្ធឯកភាពមួយសម្រាប់អនុវត្តនៅគ្រប់ក្រសួង ស្ថាប័នដែលបានផ្ទេរមុខងារកន្លងមក និងសម្រាប់ការផ្ទេរមុខងារក្នុងរយៈពេលបន្តទៀត។

- ប្រជាពលរដ្ឋនៅតំបន់មួយចំនួនពុំទាន់ទទួលបាននូវការផ្តល់សេវារដ្ឋបាល តាមយន្តការច្រកចេញចូលតែមួយ ប្រការនេះទាមទារឱ្យមានការបន្តពង្រឹង និងពង្រីកយន្តការផ្តល់សេវាតាមច្រកចេញចូលតែមួយនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ដើម្បីផ្តល់លទ្ធភាពឱ្យប្រជាពលរដ្ឋទទួលបានសេវារដ្ឋបាលទាំងនេះប្រកបដោយតម្លាភាព ឆាប់រហ័ស និងមានសមធម៌។

## ៥. ការគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌបានតម្រូវឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិទទួលបានធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិសម្រាប់អនុវត្តតួនាទី ភារកិច្ច និងមុខងារនានាដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចទទួល និងអាចកៀរគរធនធានសមស្របសម្រាប់ការផ្តល់សេវា និងការអភិវឌ្ឍនៅតាមមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ទាមទារឱ្យមានការរៀបចំបង្កើតនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមួយដែលលើកកម្ពស់ស្វ័យភាព តម្លាភាព សុចរិតភាព និងគណនេយ្យភាពក្នុងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានទាំងនោះ។ ជាមួយគ្នានេះ ប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវរៀបចំ និងដាក់ឱ្យអនុវត្តដើម្បីធានាឱ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗអាចកំណត់បាននូវចក្ខុវិស័យ កិច្ចការជាអាទិភាពនានាដែលត្រូវអនុវត្ត និងសម្រេចឱ្យបាននៅក្នុងអាណត្តិរបស់ខ្លួន ព្រមទាំងធ្វើជាមូលដ្ឋានក្នុងការកៀរគរ និងការវិភាជធនធានសម្រាប់ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋចំទិសដៅ និងមានប្រសិទ្ធភាព។

ដើម្បីសម្រេចបាននូវគោលបំណងនេះ កម្មវិធីជាតិបានកំណត់នូវកិច្ចការសំខាន់ៗដែលត្រូវអនុវត្តតាមដំណាក់កាលនីមួយៗ ដែលក្នុងនោះរួមមាន៖

១) ការរៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្តសម្រាប់ការរៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

២)ការរៀបចំបង្កើតប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

៣)ការរៀបចំ និងដាក់ឱ្យអនុវត្តនូវយន្តការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌ

៤)ការបង្កើតប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ

***ក. វឌ្ឍនភាព***

ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ហូតមកដល់ពេលបច្ចុប្បន្ននេះ មានសមិទ្ធផលជាច្រើនពាក់ព័ន្ធការរៀបចំប្រព័ន្ធគ្រប់គ្រងធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ដែលក្នុងនោះរួមមាន៖

- ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ អនុម័ត និងដាក់ឱ្យប្រើប្រាស់ ដើម្បីផ្តល់ក្របខ័ណ្ឌគតិយុត្ត និងគោលការណ៍នានាសម្រាប់ការរៀបចំបង្កើតប្រភពធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះ។
- អនុលោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លិខិតបទដ្ឋានគតិយុត្តជាច្រើនពាក់ព័ន្ធនឹងការបង្កើតមូលនិធិក្រុង ស្រុក និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ យន្តការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ ប្រភពចំណូលផ្ទាល់នៅមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តជាបន្តបន្ទាប់។
- ក្នុងក្របខ័ណ្ឌនៃការធ្វើវិមជ្ឈការហិរញ្ញវត្ថុចាប់ពីឆ្នាំ២០០២ ហូតមកដល់ឆ្នាំ២០១៧ ពេលនេះ រាជរដ្ឋាភិបាលបានផ្ទេរថវិការដ្ឋសរុបចំនួន**៨.១១២ពាន់លានរៀល**សមមូលនឹងប្រមាណជាង**២.០០០លានដុល្លា** ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ក្រោមឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្នុងចំណោមថវិកានេះ រួមមានមូលនិធិឃុំ សង្កាត់ចំនួនប្រមាណជាង ២.៤៦៧ពាន់លានរៀល សមមូលនឹង៦០៩លានដុល្លា (គិតពីឆ្នាំ២០០២ដល់ឆ្នាំ២០១៧) មូលនិធិក្រុង ស្រុកចំនួនប្រមាណជាង៤៥៣ពាន់លានរៀល សមមូលនឹង១១១លានដុល្លា (គិតពីឆ្នាំ២០១៣ដល់ឆ្នាំ២០១៧) និងថវិការាជធានី ខេត្តចំនួនប្រមាណជាង៥.១៩១ពាន់លានរៀល សមមូលនឹង១.២៨១លានដុល្លា គិតពីឆ្នាំ២០០៩ដល់ឆ្នាំ២០១៧)។
- ធនធានមូលនិធិដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានគ្រប់គ្រង ចាត់ចែង ប្រើប្រាស់តាមគោលការណ៍ និងនីតិវិធីដែលបានកំណត់សម្រាប់ការផ្តល់សេវាសាធារណៈ និងរៀបចំអនុវត្តគម្រោងការអភិវឌ្ឍមូលដ្ឋាននានាជាច្រើន (១.៨០០គម្រោងក្នុង១ឆ្នាំ។) ដើម្បីបម្រើផលប្រយោជន៍ជាក់ស្តែងរបស់ប្រជាពលរដ្ឋ។ គម្រោងអភិវឌ្ឍមូលដ្ឋានទាំងនោះរួមមាន ដូចជា ផ្លូវលំជនបទ (ផ្លូវដី ផ្លូវក្រួសក្រហម ផ្លូវបេតុង និងស្ពាន) ប្រព័ន្ធស្រោចស្រព (ប្រឡាយ និងសំណង់សិល្បការផ្សេងៗ) អនាម័យជនបទ (លូទឹកស្អុយ បង្គន់ និងប្រព័ន្ធបង្ហូរទឹក) ការផ្គត់ផ្គង់ទឹកស្អាត (អណ្តូង ស្រះ និងប្រព័ន្ធបំពង់ទុយោ) សំណង់ផ្សេងៗ ទៀត

(អគារសាលារៀន អគារសុខាភិបាល អគារសង្គម សំណង់ផ្សារ និងសំណង់សម្រាប់ការពារទឹកជំនន់ ការថែទាំបណ្តាញអគ្គិសនី បណ្តាញបង្ហូរសំណល់រាវតាមទីប្រជុំជន) ជាដើម។

- យន្តការសម្រាប់ផ្ទេរមូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌនានាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកំពុងត្រូវបានរៀបចំ ដែលក្នុងនោះរួមមាន យន្តការផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ប្រើប្រាស់លើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារដែលបានផ្ទេរឱ្យ និងយន្តការផ្ទេរធនធានមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាការផ្តល់ហិរញ្ញប្បទានបន្ថែមទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងលក្ខណៈជាការប្រកួតប្រជែងសម្រាប់អនុវត្តគម្រោងវិនិយោគសាធារណៈនានា។
- ប្រភពចំណូលផ្ទាល់នៅមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការចែករំលែកចំណូលពន្ធ និងមិនមែនសារពើពន្ធរវាងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ត្រូវបានសិក្សា និងរៀបចំ ដោយបានប្រគល់ពន្ធលើចំណូលឈ្នួលអចលនទ្រព្យ និងពន្ធលើអចលនទ្រព្យឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងកំណត់ឱ្យរដ្ឋបាលរាជធានី ខេត្តចែករំលែកចំណូលសារពើពន្ធទាំងនេះក្នុងអត្រា៣%ឱ្យទៅរដ្ឋបាលក្រុង ស្រុក និង១%ឱ្យទៅរដ្ឋបាលឃុំ សង្កាត់។
- ប្រព័ន្ធកសាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមបែបវិមជ្ឈការ និងការចូលរួមរបស់ប្រជាពលរដ្ឋក៏ត្រូវបានរៀបចំ ដាក់ឱ្យអនុវត្ត និងកែលម្អជាប្រចាំ ដើម្បីធានាឱ្យកិច្ចដំណើរការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានលក្ខណៈសមស្របទៅនឹងប្រភេទ ឬចរិតលក្ខណៈផ្សេងៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ព្រមទាំងកាន់តែមានការចូលរួមប្រកបដោយអត្ថន័យរបស់ប្រជាពលរដ្ឋទាំងក្នុងកិច្ចដំណើរកសាង និងការអនុវត្តផែនការទាំងនោះ។

ជារួម ធនធានហិរញ្ញវត្ថុដែលបានវិភាជ និងផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានការកើនឡើងជាលំដាប់។ គិតជាមធ្យម មូលនិធិឃុំ សង្កាត់មានការកើនឡើងប្រចាំឆ្នាំជាមធ្យមចំនួន១៦% ចាប់តាំងពីឆ្នាំ២០១៣មក មូលនិធិក្រុង ស្រុកមានការកើនឡើងប្រចាំឆ្នាំជាមធ្យមចំនួន២៣%ចាប់តាំងពីឆ្នាំ២០១៤មក និងថវិការាជធានី ខេត្តបានកើនឡើងប្រចាំឆ្នាំជាមធ្យមចំនួន១៨%ចាប់តាំងពីឆ្នាំ២០១៥មក។

**៩. បញ្ហាប្រឈម**

ទោះបីមានវឌ្ឍនភាពជាច្រើនអំពីការធ្វើវិមជ្ឈការហិរញ្ញវត្ថុក៏ដោយ ក៏ប៉ុន្តែនៅមានបញ្ហាប្រឈមសំខាន់ៗ មួយចំនួនដែលត្រូវបន្តដោះស្រាយមានដូចជា ៖

- រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ពុំទាន់មានធនធានសមស្របសម្រាប់បំពេញមុខងាររបស់ខ្លួនឱ្យបានពេញលេញនៅឡើយ ទោះបីជាទំហំនៃមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់មានការកើនឡើងជាលំដាប់ក៏ដោយ។ ការរីកចម្រើនយ៉ាងលឿនផ្នែកសេដ្ឋកិច្ច និងសង្គមបានធ្វើឱ្យមានការកើនឡើងនូវតម្រូវការជាអាទិភាពនានារបស់ប្រជាពលរដ្ឋ ដែលប្រការនេះចាំបាច់ត្រូវពិនិត្យលទ្ធភាពក្នុងការបង្កើនធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់បន្ថែមទៀត ដើម្បីធានាឱ្យរដ្ឋបាលមូលដ្ឋានទាំងនេះ មានលទ្ធភាពក្នុងការឆ្លើយតបទៅនឹង

តម្រូវការរបស់ប្រជាពលរដ្ឋតាមមូលដ្ឋានប្រកបដោយការជឿជាក់។

- ទន្ទឹមនឹងធនធានហិរញ្ញវត្ថុនៅមានកម្រិតពុំទាន់អាចឆ្លើយតបបានទៅនឹងតម្រូវការចាំបាច់ជាអាទិភាពនានានៅមូលដ្ឋាន បែបបទ នីតិវិធីសម្រាប់ការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ក៏នៅមានភាពស្មុគស្មាញ សាំញ៉ាំ និងមានលក្ខណៈការិយាធិបតេយ្យ ដែលពុំទាន់ធានាដល់ការពង្រឹងស្វ័យភាព និងឆន្ទានុសិទ្ធិពេញលេញរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់។ ប្រការនេះ បណ្តាលឱ្យការប្រើប្រាសធនធានហិរញ្ញវត្ថុទាំងនោះមិនអាចសម្រេចបានតាមផែនការ និងការអនុវត្តគម្រោងប្រចាំឆ្នាំនានាមានភាពយឺតយ៉ាវ។
- ការវិភាជធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ចាំបាច់ត្រូវផ្តល់អាទិភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានតួនាទីផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។ ប្រការនេះ តម្រូវឱ្យមានការពិនិត្យឡើងវិញលើការវិភាជធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ តាមតួនាទីសមស្របរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះ។

## III. ទិសដៅរយៈពេល៣ឆ្នាំបន្ទាប់

ផ្អែកលើសមិទ្ធផល និងបញ្ហាប្រឈមនានាដូចបានរៀបរាប់ខាងលើ គ.ជ.អ.ប ដោយមានការលេខាធិការដ្ឋាន គ.ជ.អ.ប. ជាសេនាធិការ បានសម្របសម្រួលកិច្ចដំណើរការរៀបចំផែនការអនុវត្ត៣ឆ្នាំដំណាក់កាលទី៣ "ផអ៣ទី៣" ដោយមានការចូលរួមធ្វើការសិក្សា វិភាគ ពិភាក្សា និងពិគ្រោះយោបល់ពីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ដើម្បីកំណត់នូវគោលបំណងជាក់លាក់ និងសកម្មភាពជាអាទិភាពចម្បងៗដែលត្រូវបន្តអនុវត្តក្នុងរយៈពេល៣ឆ្នាំដំណាក់កាលចុងក្រោយនៃកម្មវិធីជាតិ។

គោលបំណងជាក់លាក់ដែលត្រូវសម្រេចឱ្យបាននៅក្នុងរយៈពេល៣ឆ្នាំដំណាក់កាលចុងក្រោយនៃកម្មវិធីជាតិ គឺ " **រដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានស្វ័យភាព និងគណនេយ្យភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន**"។ ដើម្បីធានាដល់ការសម្រេចបាននូវគោលបំណងខាងលើ គ.ជ.អ.ប បានកំណត់នូវសកម្មភាពជាអាទិភាពដូចខាងក្រោម៖

**ទី១៖** បន្តការពង្រឹងការគ្រប់គ្រងការងារកំណែទម្រង់ ដើម្បីពង្រឹងភាពជាម្ចាស់របស់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័នទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងការដឹកនាំ ការសម្របសម្រួល ការគ្រប់គ្រង និងការអនុវត្តកិច្ចដំណើរការកំណែទម្រង់ ដោយក្រសួង ស្ថាប័ននានា និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវដាក់បញ្ចូលនូវកម្មវិធីកំណែទម្រង់ស្នូល ជាផ្នែកមួយនៃផែនការសកម្មភាព ថវិកាទាំងរយៈពេលខ្លី និងរយៈមធ្យមទៅរយៈពេលវែងទៅក្នុងផែនការយុទ្ធសាស្ត្រសកម្មភាព និងផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ព្រមជាមួយនេះ ក៏ត្រូវខិតខំបង្កើនកិច្ចសហការក្នុងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងផ្នែកឯកជនដើម្បីធានាដល់ការកៀរគរការចូលរួម និងគាំទ្រដល់កិច្ចដំណើរការកំណែទម្រង់នេះឱ្យកាន់តែមានភាពសកម្ម និងរស់រវើកបន្ថែមទៀត។ បន្តពង្រឹងការធ្វើសុខដុមនីយកម្មនូវកម្មវិធីកំណែទម្រង់អភិបាលកិច្ចសំខាន់ៗ រួមមានកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

និងកំណែទម្រង់តាមវិស័យ ដើម្បីឱ្យកាន់តែមានភាពផ្សារភ្ជាប់គ្នា កាត់បន្ថយចំណាយប្រតិបត្តិការ និងលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តការងារកំណែទម្រង់ទាំងនេះ។ កម្មវិធីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការនឹងបន្តពង្រឹងកិច្ចសហការជាមួយកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីលើកកម្ពស់ដល់ការអភិវឌ្ឍគោលនយោបាយ ការគាំទ្រ និងត្រួតពិនិត្យការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការកំណត់ឡើងវិញនូវមុខងារ និងការទទួលខុសត្រូវរវាងក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលដំណើរការនេះទាមទារត្រូវធ្វើការពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធរបស់អង្គភាពនានានៃក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។ ជាមួយគ្នានេះ កម្មវិធីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការក៏នឹងបន្តពង្រឹងកិច្ចសហការជាមួយកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីបង្កើនប្រសិទ្ធភាព និងកិច្ចប្រតិបត្តិការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងធានាបាននូវគុណតម្លៃនៃថវិកា។

**ទី២៖** បន្តពង្រឹង និងកែសម្រួលរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីកំណត់នូវតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗឱ្យកាន់តែមានភាពច្បាស់លាស់ស្របតាមប្រភេទ និងចរិតលក្ខណៈផ្សេងៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះ ដើម្បីធានាដល់ការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗកាន់តែមានលក្ខណៈសមស្រប និងមានប្រសិទ្ធភាព ព្រមទាំងដើម្បីលើកកម្ពស់ស្វ័យភាព និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានកាន់តែមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គម និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យកាន់តែមានភាពល្អប្រសើរឡើង។ ក្នុងន័យនេះ ប្រព័ន្ធ និងយន្តការបំពេញការងាររបស់ក្រុមប្រឹក្សាគ្រប់ថ្នាក់នៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធ្វើការពិនិត្យមើលឡើងវិញ និងកែលម្អឱ្យបានសមស្រប ដើម្បីលើកកម្ពស់ការសម្របសម្រួលគ្នាក្នុងក្រុមប្រឹក្សាដែលមានសមាសភាពមកពីគណបក្សនយោបាយផ្សេងៗគ្នា និងការពង្រឹងតួនាទីរបស់ក្រុមប្រឹក្សាក្នុងការធានាឱ្យមានការចូលរួម និងការពិគ្រោះយោបល់យ៉ាងពេញលេញពីប្រជាពលរដ្ឋ សហគមន៍នានានៅមូលដ្ឋាន អង្គការសង្គមស៊ីវិល ផ្នែកឯកជន ស្ត្រី យុវជន ក្រុមជនងាយរងគ្រោះលើគ្រប់កិច្ចការ មធ្យោបាយក្នុងការកំណត់អំពីតម្រូវការ ការឆ្លើយតប ព្រមទាំងគុណភាព ប្រសិទ្ធភាពនៃការផ្តល់សេវា និងការអភិវឌ្ឍនៅរដ្ឋបាលថ្នាក់ក្រោមជាតិទាំងមូល។ ទន្ទឹមគ្នានេះ យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិក៏នឹងត្រូវបន្តពង្រឹង ដើម្បីលើកទឹកចិត្ត និងផ្តល់ការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងស្តង់ដាសេវាសាធារណៈ និងស្តង់ដាការងារដែលបានកំណត់ឱ្យកាន់តែបានល្អប្រសើរឡើង។

**ទី៣៖** បន្តលើកកម្ពស់ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការរៀបចំ និងដាក់ឱ្យអនុវត្តនូវប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមបែបវិមជ្ឈការដែលធានាដល់ការផ្តល់សិទ្ធិអំណាចកាន់តែច្រើនឡើងឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើស ការតែងតាំង ការដាក់ពិន័យ និងកិច្ចការផ្សេងៗទៀតពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិក សំដៅធានាឱ្យបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបំពេញការងាររបស់ខ្លួនក្រោមការទទួលខុសត្រូវរបស់រដ្ឋ

បាលថ្នាក់ក្រោមជាតិ និងត្រូវមានគណនេយ្យភាពចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាមួយគ្នានេះ អភិក្រម និងវិធីសាស្ត្រអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក៏នឹងត្រូវពិនិត្យ និងកែលម្អតាមរយៈការរៀបចំ និងដាក់ឱ្យដំណើរការនូវសាលាជាតិរដ្ឋបាលមូលដ្ឋាន និងស្ថាប័នអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈ អចិន្ត្រៃយ៍ និងជាប្រព័ន្ធអភិវឌ្ឍសមត្ថភាពដែលមានកម្មវិធី និងស្តង់ដាជាក់លាក់។ ក្រៅពីនេះ ការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវបន្តផ្តោតទៅលើការបណ្តុះនូវគំនិតផ្តួចផ្តើមប្រកបដោយភាពច្នៃប្រឌិតថ្មីៗ និងជំនាញជាក់លាក់ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានស្របតាមស្តង់ដា ស្ថានភាព និងតម្រូវការជាក់ស្តែងរបស់មូលដ្ឋាននីមួយៗ ។

**ទី៤៖** បន្តជំរុញការផ្ទេរមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសក្នុងវិស័យអាទិភាពនានាដែលបានសម្រេចដោយរាជរដ្ឋាភិបាលទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយភ្ជាប់ជាមួយនូវការផ្ទេរសិទ្ធិអំណាច ការទទួលខុសត្រូវ ធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងសមត្ថភាពជាក់លាក់ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្លាយជាស្ថាប័នអភិបាលកិច្ចដែលមានលទ្ធភាព និងសមត្ថភាពក្នុងការគ្រប់គ្រង ចាត់ចែងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានដោយផ្ទាល់ជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រសួង ស្ថាប័ននៅថ្នាក់ជាតិនឹងមានតួនាទីសំខាន់ក្នុងការរៀបចំគោលនយោបាយ លិខិតបទដ្ឋាន ស្តង់ដារសេវា ការអភិវឌ្ឍសមត្ថភាព និងការតាមដានត្រួតពិនិត្យ និងផ្តល់ការគាំទ្រ។ ជាមួយគ្នានេះ យន្តការផ្តល់សេវាតាមច្រកចេញចូលតែមួយនឹងត្រូវបន្តពង្រឹង និងពង្រីកទៅគ្រប់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ទាំងអស់ទូទាំងប្រទេស ដើម្បីបង្កលក្ខណៈកាន់តែងាយស្រួលជូនប្រជាពលរដ្ឋក្នុងការទទួលបានសេវាឆាប់រហ័ស តម្លាភាព ប្រសិទ្ធភាព និងគណនេយ្យភាព។

**ទី៥៖** បន្តជំរុញការធ្វើវិមជ្ឈការហិរញ្ញវត្ថុ ដើម្បីធានាដល់ការបង្កើនធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងធនធានហិរញ្ញវត្ថុធន្ទានុសិទ្ធិ និងធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ និងប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងបន្តកែលម្អប្រព័ន្ធ និងពង្រឹងសមត្ថភាពគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានហិរញ្ញវត្ថុ និងសមត្ថភាពសមស្របក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុទាំងនោះ ដើម្បីដោះស្រាយបញ្ហា និងឆ្លើយតបនឹងតម្រូវការនានានៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ បន្តកិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើនអត្រាចូលរួមធនធានពីថវិការដ្ឋទៅក្នុងមូលនិធិឃុំ សង្កាត់ពី២,៨%នៅឆ្នាំ២០១៨ទៅ៣,៤%នៅឆ្នាំ២០២៣ និងការបង្កើនអត្រាចូលរួមធនធានពីថវិការដ្ឋទៅក្នុងមូលនិធិក្រុង ស្រុកពី១%នៅឆ្នាំ២០១៨ទៅ១,៥%នៅឆ្នាំ២០២៣។

## IV. សេចក្តីសន្និដ្ឋាន

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការជាកំណែទម្រង់ផ្នែកអភិបាលកិច្ចដ៏មានសារសំខាន់របស់រាជរដ្ឋាភិបាល ដែលបានអនុវត្តចាប់តាំងពីឆ្នាំ២០០១មក និងបានបង្កើតនូវសមិទ្ធផលជាច្រើនពាក់ព័ន្ធទៅនឹងការកែសម្រួលឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងនីតិវិធីបំពេញការងាររបស់រដ្ឋបាលថ្នាក់

ក្រោមជាតិ ដោយឈរលើគោលការណ៍នៃវិមជ្ឈការ និងវិសហមជ្ឈការតាមបែបប្រជាធិបតេយ្យ។ ផ្អែកលើសមិទ្ធផលនៃការអនុវត្តកំណែទម្រង់នេះក្នុងរយៈពេលជិត២ទសវត្សរ៍កន្លងមក បានបង្ហាញឱ្យឃើញថា កំណែទម្រង់នេះបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការចាំបាច់ និងដោះស្រាយបាននូវបញ្ហាប្រឈមជាអាទិភាពនានានៅតាមមូលដ្ឋានផ្សេងៗគ្នា ដែលប្រការនេះបានចូលរួមចំណែកយ៉ាងមានប្រសិទ្ធភាពដល់ការលើកស្ទួយជីវភាពរស់នៅ គុណភាពជីវិតរបស់សហគមន៍នៅមូលដ្ឋាន និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធិភាព បរិយាប័ន្ន និងសមធម៌សង្គម។

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការត្រូវបានផ្តួចផ្តើម រៀបចំ ដឹកនាំ គ្រប់គ្រងដោយរាជរដ្ឋាភិបាល ផ្អែកតាមបរិបទផ្នែកនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់កម្ពុជា។ កម្មវិធីកំណែទម្រង់នេះត្រូវបានរៀបចំ និងអនុវត្តតាមដំណាក់កាលៗ ដោយមានការចូលរួមពីក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ផ្នែកឯកជន និងអ្នកពាក់ព័ន្ធនានា។ ក្នុងរយៈពេលជិត២ទសវត្សរ៍កន្លងមកនេះ រាជរដ្ឋាភិបាលបានប្រើប្រាស់ថវិកាសរុបប្រមាណជាង**៨.១១២ពាន់លានរៀល** សមមូលនឹងប្រមាណជាង**២.០០០លានដុល្លា** សម្រាប់ការគ្រប់គ្រង ចាត់ចែង និងអនុវត្តកិច្ចដំណើរការកំណែទម្រង់ដ៏មានសារៈសំខាន់នេះ។

ទោះបីកំណែទម្រង់នេះមានការវិវឌ្ឍទៅមុខជាលំដាប់ស្របតាមដំណាក់កាលនីមួយៗ ដូចបានកំណត់នៅក្នុងកម្មវិធីជាតិ រួមជាមួយនឹងការបង្កើតបាននូវសមិទ្ធផលជាច្រើនគួរឱ្យកត់សម្គាល់ក៏ដោយ ក៏បច្ចុប្បន្ន កំណែទម្រង់នេះបាន និងកំពុងឈានចូលដល់ដំណាក់កាលកាន់តែស៊ីជម្រៅ និងកាន់តែសាំញ៉ាំទាំងក្នុងកិច្ចការនយោបាយ និងផ្នែកបច្ចេកទេស ដែលទាមទារឱ្យបន្តពង្រឹងការប្តេជ្ញាចិត្តខាងនយោបាយក្នុងរាជរដ្ឋាភិបាលទាំងមូល និងការពង្រឹងកិច្ចសហការ ការចូលរួម និងការគាំទ្រឱ្យកាន់តែខ្លាំងក្លាបន្ថែមទៀតក្នុងការបន្តអនុវត្តកិច្ចដំណើរការកំណែទម្រង់ក្នុងដំណាក់កាលទី៣នៃកម្មវិធីជាតិ ដើម្បីធានាឱ្យប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានប្រសិទ្ធភាព កាន់តែឆ្លើយតប និងកាន់តែមានគណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋ។